ឯងបានសំរាកតែដោយការនឹករលឹកពួកម៉ាកឯងខ្លាំងពេកគ្នានៅតែអង្គុយជិតមើលទៅពួកម៉ាកឯងរហូត។ ហើយដឹងទេថាភាពត្រជាក់របស់ពួកម៉ាកឯងនៅយប់នោះ តាមពិតទៅ គឺមកពីគ្នាតែប៉ុណ្ណោះ។ គ្នាបានគិតថាចំហាយត្រជាក់របស់គ្នា វាប្រហែលជាមិនត្រជាក់ដូចទឹកកកនៅទីក្រុងប៉ារីសនោះទេ គ្នាគិតថាទីក្រុងដែលពួកម៉ាកឯងបានទៅរៀនត្រជាក់ជាងនេះ ទៅទៀតណោះ មែនទេ?។ យ៉ាងណាក៏ដោយគ្នាសប្បាយ សើចរហូតនៅពេលដែលបាន ធ្វើបាបពួកម៉ាកឯងនៅរាត្រីនោះ ហាំ....ហាំ។

តាមការសង្កេតរបស់គ្នា គ្នាដឹងយ៉ាងច្បាស់ថានៅពេលដែលពួកម៉ាកឯង បានទទួលដំណឹងថាគ្នាបានស្លាប់មក ពួកម៉ាកឯងក៏មានសេចក្តីទុក្ខយ៉ាងខ្លាំងដែរ ហើយតែងមើលរូបថតរបស់គ្នានៅលើកញ្ចក់កុំព្យូទ័រតែរហូត ជាងនេះទៅទៀតពួកម៉ាកឯងក៏មិនដែលបេះខ្លាចខ្មោចគ្នាឡើយកាលពីពួកម៉ាកឯងនៅស្រុកបារាំងសេសនោះ។

តែនៅពេលដែលពួកម៉ាកឯងបានមកដល់ស្រុកកំណើតវិញ គ្នារីករាយ ព្រោះតែគ្នាអាចធ្វើឲពួកម៉ាកឯងខ្លាចគ្នាខ្លះ។ តាមការពិតទៅគ្នាគ្មានបំណងអាក្រក់នោះទេ គ្នាគ្រាន់តែចង់ប្រលែងលេងនិងពួកម៉ាកឯងតែប៉ុណ្ណោះ។

នៅរាត្រីនោះដែរ គ្នាបានសំកាំងខ្លួនសើចតែម្នាក់ឯងនៅពេលដែលឃើញពួកម៉ាកឯង ប្រឹងបើកភ្នែកប្រឹមៗ សំលឹងទិដ្ឋភាពនៅក្នុងបន្ទប់ងងឹតឈឹងនោះ ដោយសេចក្តីខ្លាចរអារ។ ពួកម៉ាកឯងមើលគ្នាមិនឃើញទេ តែតាមពិតគ្នាដែលមានសំលៀកបំពាក់និង ទទ្ធរស្បែពណ៌ស ព្រមជាមួយនិងភ្នែងពណ៌ក្រហមខ្វី បាននឹងកំពុងតែនៅជាប់និងមុខពួកម៉ាកឯង តែពួកម៉ាកឯងធ្វើដើយមិនដឹងខ្លួន។ យប់នោះគ្នានៅលេងប្រលែងជាមួយពួកម៉ាកឯង រហូតដល់ពួកម៉ាកឯងទ្រាំមិនបាននិងការខ្លាចហើយបានស្ទុះទៅបើកភ្លើងភ្លឺពេញផ្ទះ។ កាលនោះគ្នាខឹងណាស់ពេលដែលមានពន្លឺយ៉ាងនេះព្រោះតែគ្នាមិនអាចនៅលេងជាមួយពួកម៉ាកឯងបន្តទៀតបាន។

គ្នានិយាយតែម្នាក់ឯងថា៖

**«អាក្បាលខូច! វាខ្លាចឯងរត់ទៅបើកភ្លើង! អត់អីទេអាអូន! ស្អែកមកលេងទៀតហាំ!»**

និយាយបានប៉ុណ្ណេះគ្នាក៏ចេញត្រលប់មកផ្ទះមកទាំងស្នាមញញឹមទៅ។





គ្នាពិតជាពេញចិត្តនិងពួកម៉ាកឯងណាស់ នៅពេលដែលពួកម៉ាកឯងតែងបានមកលេងផ្ទះរបស់គ្នាជាញឹកញាប់នោះ ហើយនៅពេលដែលពួកម៉ាកឯងមកលេងម្តងៗ នោះហើយដែលគ្នាមិនអាចបន្តតាំងសមាធិប្រចាំថ្ងៃបាន។

គ្នាចេះតែចង់អង្គុយមកសំលឹងមើលពួកម៉ាកឯងដែលកំពុងតែអុជធូបរំលឹកដល់ឈ្មោះគ្នា។ ប្រសិនបើគ្នានៅរស់ឬគ្នាអាចនិយាយលេងជាមួយពួកម៉ាកឯងដូចពីមុនវិញ គ្នានឹងប្រកាសប្រាប់លោកនេះថាចំណងមិត្តភាពរបស់យើងទាំងពីរនឹងគ្មានថ្ងៃអវសាន្តបានឡើយ។

គ្នាក៏សូមអគុណពួកម៉ាកឯងដែរ ដែលខំផ្ញើរបស់របរជាច្រើនមកដល់គ្នា តាមរយៈព្រះសង្ឃដែលជាអ្នកមានបុណ្យនៃយើង។ អំពើល្អទាំងនេះគ្នាមិនដែលបានបំភ្លេចម្តងណាឡើយ។ តែគ្នាចង់ផ្តាំមួយបើពួកម៉ាកឯងផ្ញើរមកគ្នាលើកក្រោយ កុំភ្លេចវីុយ ស៊ីឌីចេញថ្មីៗដែលគ្នាពេញចិត្ត អ្ហើ! ដូចពួកម៉ាកឯងដឹងហើយថាគ្នាចូលចិត្តអ្វីនោះ។ កុំធ្វើពើវីុយប្រយ័ត្នគ្នាទៅរករឿងណា! ចាន់ណារិនឯងដឹងទេ? មួយសប្តាហ៍ដែលពួកម៉ាកឯងនៅក្នុងស្រុកនោះ គ្នាតែងតែទៅមើលពួកម៉ាកឯងស្ទើរជារៀងរាល់ថ្ងៃ ហើយគ្នាពិតជាអាណិតពួកម៉ាកឯងណាស់ ដែលខំប្រឹងគេចសាលា ប្រឹងប្រែងចំណាយលុយកាក់ក៏ព្រោះតែចង់មកមើលផ្ទះរបស់គ្នា។ ពេលដែលគ្នាគិតពីរឿងនេះ វាពិតជាធ្វើឲគ្នាអួលដើមក ព្រោះកាលពីពេលដែលគ្នានៅរស់ គ្នាមិនសូវបានយកចិត្តទុកដាក់ពួកម៉ាកឯងឲបានប្រសើរនោះទេ។ គ្នាពិតជាស្តាយណាស់ចាន់ណារិន! ហើយគ្នាក៏អាណិតពួកឯងដែរតែធ្វើម៉េចបើគ្នាត្រូវអស់កម្មនៅពេលនេះនោះ។

អូ្ហ!និយាយឥចឹងគ្នាចង់ប្រាប់ពួកម៉ាកឯងដែរថាមានពេលមួយដែលពួកម៉ាកឯងបានទៅលេងផ្ទះរបស់គ្នាជាមួយក្រុមគ្រួសារ។ កាលនោះដឹងទេ គ្នាមិនដឹងនិយាយថាម៉េចឲពួកម៉ាកឯងទេព្រោះគ្នានៅក្នុងផ្ទះមិនអាចចេញមកក្រៅបានដោយសារតែមានពន្លឺព្រះអាទិត្យ។ គ្នាអង្គុយមើល ពួកម៉ាកឯងកំពុងតែដុតធូប គ្នាស្រែកក៏ពួកម៉ាកឯងមិនលឺ គ្នាយកដុំថ្មទៅគប់ចំក្បាលក៏ពួកម៉ាកឯងមិនឈឺ។ គ្នាចង់ចោចសក់ ទាញច្រមុះពួកម៉ាកឯងក៏គ្នាធ្វើមិនបាន។ គ្នាពិតជាអស់តិរិះ តើធ្វើម៉េចដើម្បីឲពួកម៉ាកឯងបានដឹងថាគ្នានៅទីនេះកំពុងតែសើចនិងពួកម៉ាកឯង។ គ្នាបានមកអង្គុយចោងហោងយកធ្មេញខាំក្រចកហើយសើចតែម្នាក់ឯងឲក្អឹកនៅក្នុងចេតិយ។

អ្វីដែលគ្នាសើចជាងគេនៅពេលដែលឃើញពួកម៉ាកឯង មានទឹកមុខស្ងួតចង់ ស្រក់ទឹកភ្នែកនោះ។ គ្នានៅតែរកវិធីថាត្រូវធ្វើម៉េចឲ្យពួកម៉ាកឯងដឹងថាគ្នានៅទីនោះដែរ គិតបន្តិច គ្នាក៏នឹកឃើញគឺត្រូវបង្ហើរក្លិនខ្លួនរបស់គ្នាឲ្យពួកម៉ាកឯងបានទទួល ដូចនេះពួកម៉ាកឯង នឹងបានដឹងថាគ្នាសប្បាយចិត្តនិងឃើញពួកម៉ាកឯងមកលេងផ្នូរគ្នាមិនខាន។

គ្រាន់តែបានបញ្ចេញក្លិនសាកសពរបស់គ្នាដែលទើបបានបញ្ចុះជាងពីរសប្តាហ៍នោះភ្លាម គ្នារិតតែអង្គុយសើចទៅទៀតព្រោះបានឃើញពួកម៉ាកឯងបើកភ្នែកធំៗ ហើយក្រលេកមើលឆ្វេងមើលស្តាំ។ គ្នាពិតជារីករាយណាស់ ព្រោះគ្នាដឹងថាពួកម៉ាកឯងបានទទួលចំហាយនេះហើយ។ គ្នាខំប្រឹងស្រែកសួរពួកម៉ាកឯងនៅពេលនោះថា៖

**«ម៉េចចាន់ណារិន ខ្លួនរបស់គ្នាក្រអូបទេ?»**

គ្នាសួរពួកម៉ាកឯងប៉ុន្មានដងតែពួកម៉ាកឯងមិនឆ្លើយតបមកគ្នាវិញសោះ។គ្នាបន្តទៅទៀតថា៖

**«ចាន់ណារិនឯងអត់ចូលចិត្តក្លិននោះទេអីបានជាធ្វើមុខឥចឹង?ក្លិននេះក្រអូបណាស់ណា!»**

គ្នានិយាយបណ្តើរយកខ្នងដៃរបស់គ្នាមកហិតបណ្តើរ ហើយនៅពេលដែលគ្នាងើបមុខមកវិញស្រាប់តែគ្នាឃើញពួកម៉ាកឯងងើបឈរហើយនិយាយលាគ្នាត្រលប់ទៅផ្ទះវិញ។គ្នាខំប្រឹងស្រែកទាំងមុខស្ងួតថាកុំឲ្យពួកម៉ាកឯងប្រញាប់ទៅ ឲនៅលេងជាមួយគ្នាបន្តិចទៀតសិន តែពួកម៉ាកឯងមិនបានស្តាប់គ្នាទេ ហើយទីបំផុតពួកម៉ាកឯងបានចេញផុតអស់ទៅ ទោះបើគ្នា ខំស្រែកអង្វរយ៉ាងណា។ ពួកម៉ាកឯងទុកឲគ្នានៅអង្គុយក្នុងចេតិយតែម្នាក់ឯង។ គ្នាបាននឹករំពៃថាប្រហែលជាពួកម៉ាកឯងឈប់ចង់រាប់អានគ្នាទៀតហើយ បានជាប្រញាប់ទៅយ៉ាងនេះ។ គ្នាបានសួរខ្លួនឯងថាហេតុអ្វី? ឬមួយក៏មកពីគ្នាដែលឲក្លិនទៅពួកម៉ាកឯង ទើបបានពួកម៉ាកឯងប្រញាប់ទៅដូចនេះ។ ក្លិនខ្លួនរបស់គ្នានៅពេលនេះមិនស្អុយអ្វីទេ វាក្រអូបណាស់ ចុះម៉េចពួកម៉ាកឯងមិនចូលចិត្តទៅវិញ។ គ្នាសួរខ្លួនឯងទៀតថាឬមួយក៏ក្លិនរបស់គ្នាមិនបាន ក្រអូបដូចជាទឹកអប់ស្រុកបារាំងទើបពួកម៉ាកឯងមិនចូលចិត្តហិតយ៉ាងនេះ?

ជាការពិតកាលនៅថ្ងៃនោះ គ្នាក៏មានតូចចិត្តខឹងនិងពួកម៉ាកឯងបន្តិចដែរ ថាពួកម៉ាកឯងបានភ្លេចគ្នា នៅពេលនោះហើយដែលទឹកភ្នែករបស់គ្នាបានធ្លាក់សារជាថ្មី។ គ្នាបានរំលឹកទៅដល់អនុស្សាវរីយ៍រាប់ម៉ឺនជំពូកដែលពួកយើងបានធ្លាប់សាងរួមគ្នា។





មានពេលខ្លះពួកយើងបានទៅញ៉ាំម្ហូបនៅក្នុងហាងបាយ គុយទាវ ឬពេលខ្លះនាំគ្នាទៅដុតសាច់នៅមាត់សមុទ្រ។ ស្ទើរតែគ្រប់ពេលណាស់ទៅហើយដែលយើងញ៉ាំបាយជ្រលក់ទឹកត្រីរួមគ្នា។ ពួកយើងមិនដែលបេះខ្ទើមឬក៏ខ្លាចអ្នកណាមានរោគម្តងណាឡើយ ទោះបើនៅក្នុងស្រុកសំបូរទៅដោយជំងឺថ្លើមបេះដូងដែលឆ្លងតាមទឹកមាត់ក៏ដោយ។ នេះក៏ដោយសារពួកយើងស្រលាញ់គ្នារាប់អានគ្នាលើសពីបងប្អូនទៅទៀត។ នៅពេលខ្លះនៅពេលដែលយើងដើរសប្បាយជ្រុលជាមួយស្រីៗ ពួកយើងបាននាំគ្នាទៅជួលបន្ទប់គេងតែពីរនាក់ក៏មាន។ យើងជួបគ្នាជារៀង រាល់ថ្ងៃយើងនិយាយបង្អាប់គ្នា យើងផ្តល់យោបល់ពីគ្នាទៅវិញទៅមក តែពេលនេះប្រហែល ជាចាន់ណារិនឯងបានភ្លេចអំពើទាំងនេះអស់ទៅហើយ កាលនោះគ្នាពិតជាមានតូចចិត្តបន្តិចដែរនៅពេលដែលចាន់ណារិនឯងប្រញាប់ទៅដូចនេះ។ ទោះជាគ្នាមានចិត្តបន្តិចក៏ដោយ តែគ្នាពិតជាស្រលាញ់ពួកម៉ាកឯងយ៉ាងខ្លាំងហើយគ្រប់យប់ គ្នាតែងទៅលេងពួកម៉ាកឯងមិនដែលខានឡើយតែពួកម៉ាកឯងមិនបានដឹងអ្វីទាំងអស់ក្រៅពីមានអារម្មណ៍បន្តិចបន្តួចថាគ្នានៅជិតនោះ។ ការខឹងសម្បាទាំងនេះបានរលាយសាបសូន្យទៅវិញនៅពេលដែលពួកម៉ាកឯងបានដុតធូបនៅឯវត្តសុំកុំឲគ្នាឲក្លិនដូចមុនទៀត បើមិនដូចនេះទេពួកម៉ាកឯងនឹងមិនបាននៅលេងយូរជាមួយគ្នាឡើយ។ នៅពេលនោះហើយដែលគ្នាបានដឹងខ្លួនថាក្លិនទាំងនេះវាក្រអូបសំរាប់តែពួកខ្មោចតែប៉ុណ្ណោះ តែវាមានក្លិនផ្ទុយទៅវិញសំរាប់មនុស្សលោក។ នៅពេលដែលមានការបន់ស្រន់ពីពួកម៉ាកឯងដូចនេះ ទើបគ្នាឈប់ប្រកែប្រកាន់និងពួកម៉ាកឯងបន្តទៅទៀត ហើយឃើញទេ នៅពេលដែលពួកម៉ាកឯង មកលេងគ្នានៅថ្ងៃចុងក្រោយនោះ តើមានក្លិនទៀតទេ? ជាការពិតណាស់គឺអត់។ គ្នាដឹងថាពួកម៉ាកឯងមានការឆ្ងល់ថាហេតុអ្វី ម្សិលមុិញធំក្លិនហើយថ្ងៃនេះមិនមានក្លិនទៅវិញ? គ្នាប្រាប់តាមត្រង់ទៅចុះ គឺជាគ្នាទេដែលឲក្លិនឬអត់។ នៅថ្ងៃនោះគ្នាពិតជាសប្បាយចិត្តព្រោះបានឃើញពួកម៉ាកឯង ជាតា ដានិត រ៉ូ ភក្តី ដែលបានមកលេងផ្នូរគ្នា។ គ្នាក៏សោកស្តាយនិងពិតណាស់ថាគ្នាអាណិតពួកម៉ាក ឯងព្រោះពួកម៉ាកឯង ត្រូវត្រលប់ទៅបន្តការសិក្សានៅឯប្រទេសបារាំងវិញ នៅប៉ុន្មានម៉ោងបន្ទាប់នេះ។

គ្នាអង្គុយនៅក្នុងផ្នូរទទួលផ្សែងធូបពីអ្នកទាំងអស់គ្នាហើយគ្នាក៏បានបន់ស្រន់ឲពួកអ្នកទាំងអស់គ្នាទទួលបានសេចក្តីសុខ ជាការពិតណាស់វាបានធ្វើឲគ្នាកាន់តែខ្លោចចិត្ត នៅពេលដែលបាន

ឃើញពួកម៉ាកឯងស្រក់ទឹកភ្នែកនៅពីមុខផ្នូររបស់ខ្លាព្រោះវានឹងធ្វើឲខ្លាមិនអាចតាំងសមាធិបានស្ងប់បន្តទៀតមិនខាន។

ខ្លាបានផ្ទុះសំណើចទាំងទឹកភ្នែកនៅពេលដែលបានលឺរ៉ូនិយាយថា៖

**«តាមពិតការវាកំពុងតែមើលយើងទេតើ!កុំយំនាំឲវាសើចយើងវិញទេ?»**

**«អ្ហើមែនតើ ឯងនៅនិងតើ!»** ខ្លាឆ្លើយទាំងភ័យទាំងអរ

**«ម៉េចការ យប់ហ្នឹងចាន់ណារិនទៅវិញហើយ យើងគិតទៅរកផឹកឯណា?»**

ខ្លាមិនឆ្លើយនិងរ៉ូទៀតទេ ខ្លាអង្គុយសើចព្រោះខ្លាបានដឹងថារ៉ូមិនបានមើលឃើញខ្លាឡើយ។ គេគ្រាន់តែនិយាយលេងជាមួយខ្លាប៉ុណ្ណោះ ហើយគេនិយាយដូចនេះដើម្បីតែចង់ឲអ្នកទាំងអស់ខ្លាឈប់យំតទៅទៀត។ ខ្លាញញឹមនិងគ្រវីក្បាលទៅនិងពាក្យសំដីរបស់គេ។

មួយសន្ទុះក្រោយមក ចាន់ណារិននិងអ្នកទាំងអស់ខ្លាបានលាខ្លា ហើយបានទុកឲខ្លានៅម្នាក់ឯងនៅក្នុងផ្នូរបន្តទៅទៀត។

ខ្លួនរបស់ខ្លានៅពេលនោះញ័រអស់ហើយ ព្រោះតែចង់ទៅតាមអ្នកទាំងអស់ខ្លា តែខ្លាធ្វើមិនបានទេព្រោះតែយើងរស់នៅក្នុងភពផ្សេងគ្នាទៅហើយ។

ខ្លាអង្គុយតាំងតែពីអ្នកទាំងអស់ខ្លាមកលេងនាវេលាម៉ោងបីរសៀលរហូតដល់ម៉ោងប្រាំពីរយប់ដែលនៅពេលនោះខ្លាបានលឺសំលេងយន្តហោះ របស់ពួកម៉ាកឯង កំពុងតែបំពងជាសញ្ញាថាយន្តហោះនឹងចេញដំណើរបន្តិចទៀតនេះ។ ទឹកភ្នែករបស់ខ្លាបានហូរយ៉ាងខ្លាំង ហើយខ្លាសុំទោសដែលខ្លាមិនអាចជូនដំណើរពួកម៉ាកឯងទៅបាន។

នៅពេលដែលខ្លាកំពុងតែសញ្ជប់សញ្ជឹង យន្តហោះបានហោះកាត់វត្តសុភាឃួន ហោះកាត់ផ្នូររបស់ខ្លា។ ខ្លាយំ ខ្លាស្រែក ខ្លាពិតជាឈឺចាប់ណាស់ដែលខ្លាមិនបានឃើញ ពួកម៉ាកឯងជាលើកចុងក្រោយនេះ។ ខ្លាខំធ្មេញសំដៅស្រម៉ៃទៅរកពួកម៉ាកឯង ហើយ ខ្លាក៏បានដឹងថាពួកម៉ាកឯងក៏បាននឹងកំពុងតែសំលឹងពីលើយន្តហោះមករកផ្នូររបស់ខ្លាវិញដែរ។អ្វីដែលពួកម៉ាកឯងឈឺផ្សារទាំងប៉ុន្មានវាមិនខុសពីខ្លានោះទេ។

ខ្លាខំប្រឹងសំងំសមាធិដោយអារម្មណ៍ស្ងប់ ហើយបានប្រមូលនូវបុណ្យបារមីរបស់ខ្លាទាំងប៉ុន្មានដែលខ្លាបានសាង យកមកទុកថែរក្សារពួកម៉ាកឯង ក្នុងការធ្វើដំណើរឲបានសុខសប្បាយ។





ខ្លាបានបន់ស្រន់អស់ហើយសូមឲទេវតាគ្រប់ទិសនិងអស់លោកអ្នកមានបារមីទាំងអស់សូមជួយជំរុញចិត្តឲពួកម៉ាករបស់ខ្លាបានបន្តការសិក្សាឲបានចប់ចុងចប់ដើមនិងទៅណាមកណាមានគេអាណិតស្រលាញ់។ ខ្លាខំប្រមូលអារម្មណ៍ ការពារពួកម៉ាកឯងទាំងទឹកភ្នែកហូររហាមរហូតដល់យន្តហោះបានចេញបាត់ផុតសំលេង។

នៅយប់ដែលចាន់ណារិនឯងចេញទៅ កំហឹងទាំងប៉ុន្មានហាក់បានលេញចេញរូបរាងសារជាថ្មីខ្លាកាន់តែសោកស្តាយ ខ្លាកាន់តែខឹងហើយរកមូលហេតុដែលខ្លាបានស្លាប់ពិសេសឃាតករ។ នៅយប់ដែលចាន់ណារិនឯងចាកចេញទៅប្រទេសបារាំងវិញ កំហឹងរបស់ខ្លាបានឆាបឆេះរោលពេញរូបកាយ។ ខ្លាបានគិតថានឹងហែកមនុស្សទុរយ័សនោះជាពីរបីចំណែក ឲស្លាប់នៅពេលនោះមិនខាន។ អស់រយៈពេលយូរណាស់មកហើយ ដែលខ្លាមិនបានគិតពីរឿងគុំនំទាំងនេះហើយក៏បានភ្លេចអស់ផងដែរ។ ខ្លាមិនបានដឹង ថាហេតុអ្វីពេលនេះចិត្តរបស់ខ្លា លែងចង់ទន្ទិញធម៌ទៅវិញ។ នៅរាត្រីដ៏ស្ងាត់ពាក់កណ្តាលអាធ្រាតនោះ ខ្លាមិនបានដើបចេញពីផ្នូរដោយរូបស្អាតរបស់ខ្លានោះទេ ខ្លាបានបង្ហាញខ្លួនជាសាកសពពិតៗ ដែលបានស្លាប់រលួយជាច្រើនសប្តាហ៍។ ខ្លាបាន ហោះសំដៅយ៉ាងលឿនឆ្ពោះទៅកាន់មន្ទីឃុំឃាំងព្រៃសរ ដែលនៅមិនឆ្ងាយប៉ុន្មានពីទីផ្នូររបស់ខ្លា ក្នុងបំណងកាច់បំបាក់ករអាឃាតករឲបាននៅយប់នោះ។ ពេលដែលខ្លាបានទៅដល់មុខគុកស្រាប់តែមានអ្នកយាមពីរនាក់ អ្នកយាមដែលជាម្ចាស់ទឹកម្ចាស់ដីនៅទីនោះបានចេញមកហើយនិយាយរកខ្លាថា៖

**«តើអ្នកមកទីនេះដើម្បីយកជីវិតមនុស្សដែលបានសំលាប់អ្នកមែនទេ? បើដូចនេះអ្នកមិនអាចចូលបានទេ»**

**«តែវាបានធ្វើឲខ្ញុំឈឺចាប់ណាស់»** ខ្លាតប

**«អ្នកមិនអាចនិយាយបែបនេះបានទេ ព្រោះវាជាកម្មដែលអ្នកត្រូវសងទៅគេវិញ»**

ខ្លាមិនបានស្តាប់អ្នកយាមទាំងពីរនោះទេ ខ្លាបានហោះបុកដើម្បីចូលទៅក្នុងគុក តែត្រូវអ្នកយាមទាំងពីរបានដកដាវមួយយ៉ាងវែងមានពន្លឺយ៉ាងចិញ្ចាចបំរុងនិងកាប់បំបែកព្រលឹងរបស់ខ្លា តែពេលនោះស្រាប់តែលេចមុខបុទមវត្តីចេញហើយស្រែកឡើងព្រមគ្នាថា៖

«ឈប់សិន!»

គ្រាន់តែលឺប៉ុណ្ណឹងពួកគ្នាទាំងបីដែលបំរុងតែវាយប្រយុទ្ធគ្នានោះ ក៏នាំគ្នាឈប់ស្រឡាំងកាំងមើលមករកម្ចាស់សំលេង។បុទមបានហោះសំដៅមកជិតគ្នាហើយនិយាយឡើងថា៖

«បង! សូមបងកុំគិតពីរឿងគំនុំទៀតអី គេសំលាប់បងគេមិនរួចខ្លួននោះទេទោះនៅឋានមនុស្សលោកឬក៏ពេលដែលគេស្លាប់ទៅក៏ដោយ ឃាតករនោះនឹងទទួលទារុណកម្មដ៏ខ្លោចផ្សារ ជាទីបំផុតមិនថាផ្លូវកាយឬផ្លូវវិញ្ញាណនោះទេ» បុទមនិយាយទាំងទឹកមុខស្រពោបស្រពោន ហើយនាងបានបន្តទៀតថា៖

«តើបងបានភ្លេចបណ្តាំស្តេចយមរាជហើយមែនទេមុនពេលដែលបងមកដល់ទីនេះ? ការមកតាំងសមាធិខ្លួនឯងវាគឺជាកញ្ចក់និងជាការលាងបាបបន្តិចបន្តួចដែលបងបានសាងកាលពីបងនៅរស់បើបងទប់ចិត្តមិនបាននោះទេតើបងនឹងរួចទោសទាំងនេះបានយ៉ាងណា? ហើយបើបងមានកម្មជាប់ទោសនៅឋាននរករាប់រយឆ្នាំតើពួកយើងទាំងពីរ ដែលរងចាំបងជាយូរណាស់មកហើយនោះត្រូវធ្វើយ៉ាងណា?ឬមួយបងចង់ទុកឲពីរនាក់ខ្ញុំនៅចាំបងបន្តទៅទៀតមែនទេ?សូមបងមេត្តាអាណិតដល់ភរិយាបងទាំងពីរនេះផង ដែលតែងមានភក្តីភាពចំពោះបងតាំងតែពីរជាតិមុនមកម៉្លេះ សូមបងមេត្តាបំភ្លេចរាល់ការឈឺចាប់ទាំងនេះ មិនយូរទេ ពួកយើងទាំងអស់គ្នារួមមានអ្នកបងដានិតផងនិងបានមករស់នៅជុំគ្នាគ្មានទុក្ខព្រួយទៀតឡើយ»

កាលបើបានលឺពាក្យដ៏ពិរោះទាំងនោះ គ្នាបានក្រលេកមកមើលអ្នកទាំងពីរ ដែលគ្នានៅចាំបានថាពួកនាងជាភរិយារបស់គ្នាតាំងតែពីប្រាំរយឆ្នាំមុនមកម៉្លេះ ហើយគ្នាខំប្រមូលអារម្មណ៍ដកដង្ហើមមកជាធម្មតាវិញដោយសុំអង្វរនាងថា៖

«បងយល់ព្រម បងមិនទៅសំលាប់គេទេតែសូមឲបងបានទៅឃើញឃាតករនោះបន្តិច!»

បុទមបានងាកមករកអ្នកយាមដើម្បីអង្វរតែត្រូវពួកគេគ្រវីក្បាលដោយមិនយល់ព្រមឡើយ។ ឃើញដូចនេះវត្តីបានហូតដួងព្រលឹងរបស់នាងចេញមក ដែលមានពណ៌ក្រហមយ៉ាងចិញ្ចាំងចិញ្ចែងហើយហុចទៅឲអ្នកយាមទាំងពីរដោយនិយាយបន្ថែមថា៖

«ខ្ញុំសូមយកដួងវិញ្ញាណរបស់ខ្ញុំដាក់នៅជាមួយលោកទាំងពីរ ប្រសិនបើលោកប្តីរបស់ខ្ញុំធ្វើខុសពីច្បាប់ឋាននរក សូមលោកទាំងពីរយកវិញ្ញាណនេះទៅកំទេចចោលចុះ ព្រោះវាគ្មាន





តំលៃអ្វីទៀតទេដែលខ្ញុំត្រូវរងចាំប្តីរបស់ខ្ញុំសារជាថ្មីនោះ»

កាលបើវត្តីបាននិយាយពាក្យទាំងនេះចប់ អ្នកយាមទាំងពីរបានមើលមុខគ្នាឡេងឡង់ៗ ហើយក៏ព្រមទទួលទុកជាគ្រឿងប្រចាំដើម្បីឲគ្នាបានចូលទៅមើលឃាតករ។

មុនពេលដែលគ្នាចូលទៅខាងក្នុង គ្នាបាននិយាយទៅកាន់វត្តីថា៖

«តើវត្តីពិតជាទុកចិត្តខ្ញុំមែនទេ?»

«ខ្ញុំជាភរិយារបស់បងហើយបានរងចាំបងនៅទីនេះជាច្រើនឆ្នាំណាស់មកហើយ បើបងចង់ឲគេកំទេចវិញ្ញាណភរិយាដែលស្រលាញ់បងយ៉ាងស្មោះត្រង់នោះ សូមបងធ្វើចុះ អូនសូមប្រគល់អ្វីៗជូនបងទាំងអស់ដោយមិនស្តាយក្រោយឡើយ»

បុទមនាងមិនបាននិយាយអ្វីទេឯគ្នាវិញបានត្រឹមតែងក់ក្បាលហើយបណ្តែតខ្លួនចេញមកដោយនៅចាំជាប់ជានិច្ចនូវសំដីរបស់នាង សំដីដែលធ្វើឲគ្នាខ្លោចចិត្តអាណិតភរិយាទាំងពីរ។

គ្នាបានមកដល់បន្ទប់មួយនៅក្នុងមន្ទីឃុំឃាំង ដោយសារការចង្អុលបង្ហាញរបស់អ្នកយាមទាំងពីរ។ នៅក្នុងបន្ទប់មួយដែលមានប្រវែងតែដប់ម៉ែត្របួនជ្រុងប៉ុណ្ណោះ មានអ្នកទោសជាច្រើននាក់កំពុងតែដេកពាក់ពួនគ្នា។ យប់ស្ងាត់ប្រហែលជាម៉ោងមួយភ្លឺទៅហើយ អ្នកទោសទាំងឡាយស្ទើរតែទាំងអស់នាំគ្នាដេកលក់យ៉ាងស្កប់ស្កល់ក្រោមវាយោបក់បោកមករំភើយៗ តែសំរាប់គ្នាហាក់បានដឹងថាឃាតករដែលបានប្រហារគ្នា វានៅមិនទាន់លក់នៅឡើយទេ។ វាកំពុងតែធ្វើដេកយកដៃមកគងថ្ងាស តែនៅពេលដែលមានភាពត្រជាក់មួយបានមកជិតវា ឃាតករដ៏ឥតសាសនានោះបានបើកភ្នែកភ្លែតហាក់ទទួលដឹងថាមានរឿងអ្វីមួយបានមកដល់។ វាប្រឹងសំលឹងមកមើលជញ្ជាំងគុកតែវាមិនបានដឹងថានៅពីមុខជញ្ជាំងនោះ ខ្មោចរបស់គ្នាកំពុងតែសំកាំងមើលវានោះទេ។ វាដេកបណ្តើរទំពារស្ករកៅស៊ូបណ្តើរនិងជើងវាម្ខាងគងរលាស់យ៉ាងជាប់។ វាហាក់បីដូចជាមិនបានខ្វាយខ្វល់ក្នុងការរងចាំតុលាការកាត់ទោសវាឡើយ ហើយបើតាមតែគ្នាស្មាននៅពេលនោះប្រហែលជាវាគិតថាមិនយូនោះទេ វានឹងបានចេញពី ទ្រុងនេះមិនខាន ដោយសារតែស្រុកខ្មែរមានអំពើពុករលួយ ទោះបើវាបានធ្វើខុស តែកាលណាវាមានលុយសំរាប់ឲពួកនោះ វាប្រាកដជារួចខ្លួនជាមិនខាន ដោយប្រែពីរឿងខ្មៅមកស។ វាមានទឹកមុខ

មិនភិតភ័យហាក់បីដូចជាវាបានដឹងថា វានឹងបានសេរីភាពយ៉ាងឆាប់នៅពេលខាងមុខ ពេលដែលតុលាការរកកំហុសរបស់វាមិនឃើញឬក៏តុលាការទទួលសំណូករបស់វា។

កាយវិការរបស់វាពិតជាមិនខុសពីពពួកបងតូចបងធំដែលសង្គមខ្មែរ ឥឡូវកំពុងតែស្អប់ខ្ពើមនោះទេ។

កាលបើគ្នាបានឃើញវាភ្លាម គ្នាមានអារម្មណ៍ក្តៅក្នុងខ្លួនយ៉ាងខ្លាំង ហើយចង់ស្ទុះលើកវាមកកាច់កបំបាក់ហុតយកឈាមខ្មៅរបស់វាចេញឲអស់ពីក្នុងខ្លួន ដោយមិនឲស្រក់មួយតក់ទៅលើផែនដីដ៏ផូរផង់នៃយើង។ គ្នាពិតជាចង់ធ្វើបាបវាវិញឲសមទៅអ្វីដែលវាបានធ្វើមកលើគ្នា។ គ្នាពិតជាខឹងនិងវាណាស់ ហើយមានគំនិតចង់បង្ហាញខ្លួនប្រាណដ៏ស្អុយរលួយ មុខមាត់ហើមកំព្រឹកកំព្រាក ភ្នែកទាំងពីរសស្លេកធ្លាក់ត្រយ៉ាក ដងខ្លួនទាំងប៉ុន្មានកំពុងតែហូរស្រក់ទៅដោយទឹកនិងឈាមស្អុយឲទៅវាឃើញ តែចិត្តមួយទៀតបានគិតថាដាច់ខាតគ្នាមិនត្រូវធ្វើបាបបុទមវត្ថីដែលគ្នាខំយកដួងព្រលឹងមកទុកបញ្ឆាំដើម្បីតែគ្នាឡើយ។

នៅពេលនោះគ្នាមិនបានទៅណាឆ្ងាយពីឃាតករនោះទេ គ្នាកំពុងតែនៅសំលឹងមើលទៅមុខវាយ៉ាងជាប់ដោយកែវភ្នែកយ៉ាងមាំ។ គ្នាហារមាត់ គ្នាក្តាប់ដៃ គ្នាខាំធ្មេញទាំងសស្ងេញដោយពិតជាចង់ត្របាក់ឲខ្ទេចតែទោះយ៉ាងណាគ្នានៅតែទប់កំហឹងនោះបានដោយគ្នាសុខចិត្តនៅមួយកន្លែងមើលតែវាប៉ុណ្ណោះ។

កំពុងតែសំលឹងវាមិនដាច់ភ្នែក ស្រាប់តែពេលនោះមានខ្មោចកុមារីម្នាក់មានអាយុប្រមាណតែ១៣ឆ្នាំបានហោះមកដល់បន្ទប់ជាមួយគ្នានោះដែរ។ ទឹកមុខរបស់នាងស្លេកស្លាំង នាងស្លៀកសំលៀកបំពាក់នឹងទទូរក្រណាត់ដូចជាគ្នាដែរ។នាងបាននិយាយមករកគ្នាថា៖

**«តើពូមកទីនេះធ្វើអ្វីដែរ?»**

**«ពូមកមើលឃាតករដែលបានសំលាប់ពូយ៉ាងព្រៃផ្សៃ ចុះក្មួយវិញមកធ្វើអ្វីដែរនៅទីនេះ?»**

គ្នាបានសួរទៅនាងវិញ

**«ខ្ញុំមកសងសឹកមនុស្សដែលបានចាប់រំលោភលើរាងកាយនិងសំលាប់ខ្ញុំជាក្រោយ»**

នាងនិយាយយ៉ាងមាំហើយបានបណ្តែតខ្លួននៅពេលដំណាលគ្នានោះ ទៅកាន់បុរសម្នាក់ដែលកំពុងតែដេកជាប់នឹងឃាតករដែលសំលាប់គ្នាដែរ។





កុមារនោះពិតជាក្លាហានណាស់គ្រាន់តែនិយាយជាមួយគ្នាចប់ភ្លាម នាងបានប្រើវេទមន្តរបស់នាងដោយបង្ហាញរូបរបស់នាង។

រូបដែលមានពណ៌ប៉ៃតងខៀវខ្ចីបានផុសឡើងយ៉ាងចិញ្ចាចនៅក្នុងបន្ទប់គុគដ៏ងងឹត ហើយនាងបានចាប់ច្របាច់កអ្នកទោសដែលបានរំលោភនាងនោះ ដោយនាងបានស្រែកយ៉ាងខ្លាំងទៅកាន់បុរសនោះថា៖

**«សងជីវិតអញមកវិញមក»**

បុរសដែលនាងច្របាច់កកាលបើបានដឹងខ្លួនហើយឃើញសាកសពនាងនៅនិងមុខ បានស្រែកបានស្ទុះឲគេជួយ

**«ជួយផងខ្មោចលង។»**

បុរសនោះស្រែកហើយស្រែកទៀតដោយរត់នៅជុំវិញគុគ។ នៅពេលដំណាលគ្នានោះដែរ ពួកបិសាចដែលមានតួនាទីការពារគុគនោះបានហោះមកដល់ ហើយបានប្រទាញកុមារីកំសត់នោះចេញពីទីនោះទៅ នៅនិងមុខរបស់គ្នា។ ពួកគេបានចេញផុត ទុកឲគ្នានៅតែម្នាក់ឯងសំកាំងខ្លួននៅលើជញ្ជាំងបន្តមើលភាពចលាចលរបស់អ្នកទោសនៅក្នុងបន្ទប់គុគ។

ពួកគេម្នាក់ៗបានភ្ញាក់ដឹងខ្លួនហើយសួរទៅបុរសដែលបានឃើញខ្មោចកុមារនោះគ្រប់គ្នា។ បុរសនោះកាលបើបានឃើញនៅផ្ទាល់ភ្នែកដូចនេះ គាត់បានរៀបរាប់ទៅអ្នកទោសដូចគ្នា ដែលនៅពេលនោះឃាតករសំលាប់គ្នាក៏នៅទីនោះដែរ គាត់បាននិយាយថាគាត់ពិតជាបានឃើញកុមារីដែលគាត់បានរំលោភនោះពិតមែន។

ហើយកុមារនោះបានមកច្របាច់កបំរុងនឹងសំលាប់គាត់តែពេលដែលគាត់បានដឹងខ្លួនច្បាស់និងស្រែកឲគេជួយ នាងក៏រលាយខ្លួនបាត់ទៅវិញ។ ទោះជាមានការរៀបរាប់យ៉ាងណាក៏ដោយតែគ្មានអ្នកទោសរួមបន្ទប់ណាមួយបានជឿគាត់នោះទេ ពួកគេគ្រាន់តែនិយាយថាតាមពិតវាជាសុបិន្តអាក្រក់តែប៉ុណ្ណោះ ហើយពួកគេទាំងនោះរួមទាំងបុរសនោះផងក៏នាំគ្នាសំងំដេកបន្តទៅទៀតទៅ។ បុរសនោះមិនហ៊ានគេងមើលជញ្ជាំងបន្តទេ គាត់បានគេងអោនមុខទៅខាងក្រោមដោយយំខ្សឹកខ្សួលរកម៉ែរកឪឲមកជួយ។ គ្នាពិតជាមិនយល់ទាល់តែសោះនៅពេលដែលបានឃើញសភាពនិងលីបែបនេះ។ វាជាអំពើអាក្រក់ដែលគាត់បានធ្វើ ហើយនៅពេលដែលគេដាក់

ទោសគាត់ គាត់បែរទៅជារកម៉ែរកឪឲមកជួយទៅវិញ។

ងាកមកមើលឃាតករសំលាប់ខ្លាវិញម្តង វាមិនមាត់មិនកអ្វីទាំងអស់ វានៅស្ងៀមហើយក៏លែងទំពារស្លកៅស៊ូរដែរ។ វាខំប្រឹងសំលឹងមើលទិដ្ឋភាពនៅជុំវិញខ្លួនរបស់វា តែវានៅតែមិនដឹងថាខ្លាកំពុងតែសំលឹងនិងចង់ស៊ីសាច់វានោះឡើយ។

ពេលវេលាបានមកដល់ វាត្រូវជាពេលដែលខ្លាត្រូវត្រលប់មកកាន់ផ្ទះរបស់ខ្លាវិញ។ ខ្លាបានបង្ហោះខ្លួនយ៉ាងលឿនដើម្បីចេញមកក្រៅមកជួបនិងបុទមវត្តីវិញ។ វត្តីមានសេចក្តីត្រេរអរកាលបើបានដឹងថាខ្លាមិនបានធ្វើអ្វីឲខុសពីច្បាប់ នាងបានទទួលដួងព្រលឹងរបស់នាងវិញ ហើយពួកនាងទាំងពីរបានជូនខ្លាត្រលប់មកផ្ទះរបស់ខ្លាវិញ។

នៅពីមុខផ្ទះរបស់ខ្លា មុនពេលដែលខ្លាចូលទៅខាងក្នុង បុទមបាននិយាយឡើងថា៖

«ពេលបងចេញទៅក្រៅសូមបងកុំតែងខ្លួនអាក្រក់ឥចឹងទៀត ព្រោះបើកាលណាអ្នកដែលមានប្រជ្រុយភ្នែកអាចមើលពពួកខ្មោចបាន គេនឹងអាចមើលបងឃើញ ហើយនៅពេលនោះគេនឹងលស់ព្រលឹងស្លាប់ដោយសារបងមិនខាន!»

ខ្លាញញឹមស្ងួតដោយងក់ក្បាលទទួលយល់ព្រមពីនាង។

«សូមបងឈប់គិតពីការចងអាឃាតនោះទៅ បងឃើញទេកុមារីអំបាញ់មិញ កាលបើនាងបានប្រព្រឹត្តខុសប៉ុណ្ណឹងសោះ នាងនឹងត្រូវទទួលទារុណកម្មយ៉ាងតិចមួយរយឆ្នាំក្នុងឋាននរកមិនខាន។សូមបងទ្រាំឲបាន មិនយូរទេបងនឹងបានរួចពីទុក្ខទោសទាំងនេះមិនខាន»

ក្រោយពីពួកគេបាននិយាយចប់ពួកគេក៏បានរលាយខ្លួនបាត់អស់ទៅ ឯខ្លាវិញក៏ចូលមកកាន់ម្លូសដើម្បីបន្តការតាំងសមាធិវិញដែរ។

ចាប់តាំងពីពេលវេលានោះមក ចាប់ពីថ្ងៃដែលចាន់ណារិនឯងបានត្រលប់មកស្រុកបារាំងវិញ ខ្លាពិតជាមិនចង់ចេញទៅណាមកណាទៀតនោះទេ ព្រោះខ្លាបានគិតតាមសំដីរបស់បុទមវត្តីថាខ្លាគួរតែឈប់គិតពីរឿងរ៉ាវនៅក្នុងឋានមនុស្សហើយក៏មិនយូរដែរពួកយើងទាំងអស់គ្នានឹងបានមកជួបខ្លាវិញមិនខាន។

មានយប់ខ្លះ ខ្លាមិនបានចេញមកក្រៅលេងជាមួយពពួកខ្មោចឯទៀតនោះទេ។ ខ្លាប្រឹងតែទន្និញធម៌ទាំងឡាយ ធម៌ដែលបានធ្វើឲខ្លាបានស្បើយនូវរាល់កិលេសតណ្ហានិងការចង់បានទាំងឡាយ





ហើយពិសេសនៅពេលដែលអ្នកម្តាយ ក្រុមគ្រួសាររបស់ខ្លា និងដានិតតែងតែដុតធូបសូមឲខ្លាបានទៅចាប់កំណើតនៅភពថ្មីទៀតនោះ ខ្លាក៏កាន់តែស្ងប់ចិត្តទន្និញធម៌ហើយនិងមិនខ្វល់ខ្វាយបន្តទៅទៀតឬក៏ចង់ទៅសំលាប់មនុស្សអាក្រក់នោះដែរ។

ស្ទើរតែពេញពីរសប្តាហ៍ដែលខ្លាមិនដែលចេញក្រៅពីម្លូសសោះ រហូតដល់ពេលខ្លះមានខ្មោចផងទៃបានមកគោះទ្វាស្រែកសួរមករកខ្លាថាហេតុដូចម្តេចបានជាខ្លា មិនព្រមចេញលេងនៅក្នុងវត្តនិងគេសោះ? នៅពេលខ្លះពួកគេមានការអន់ចិត្តនិងខ្លានៅពេលដែលខ្លាមិនព្រមចេញទៅលេងនិងពួកគេ ពួកគេបានចោទថាខ្លាជាខ្មោចប្រកាន់ដូចនេះហើយបានជាមិនចេញមក។ អ្វើយពិបាកដែរ មិនថាតែនៅក្នុងឋានមនុស្សលោកទេដែលចេះខឹងសម្បា ស្លាប់ទៅជាខ្មោចទៅហើយក៏នៅចេះខឹងដែរ។

មានថ្ងៃមួយដោយមិនចង់ប្រកែកនិងពួកគេតទៅទៀត ខ្លាបានសុខចិត្តមកហោះលេងជាមួយពួកគេពីដើមឈើមួយទៅដើមឈើមួយ។ ល្បែងខ្មោចដែលខ្លាចូលចិត្តលេងសប្បាយជាងគេគឺបិតពួននិងការធ្វើមុខមាត់ឲអាក្រក់អាក្រក់គួរឲខ្លាចរអារ។

ការលេងបិតពួន ល្បែងនេះមិនខុសពីល្បែងដែលក្មេងៗគេលេងនៅឯឋានមនុស្សលោកនោះទេ តែគ្រាន់ខុសគ្នានៅត្រង់ថាពួកខ្មោចចូលចិត្តណាស់ហោះទៅពួននៅលើចុងឈើខ្ពស់ៗ រន្ធដីហើយក៏មានពេលខ្លះពួកគេទាំងនេះបានទៅពួននៅក្នុងរន្ធជន្លេនក៏មានដែរ។

នៅពេលដែលខ្លាចាំទីម្តងៗខ្លាពិតជាពិបាកណាស់ព្រោះតែពួកគេទាំងនោះពូកែលាក់ខ្លួនហើយខ្លាក៏មិនដែលបានដេញចាប់គេទាន់ម្តងណាដែរ ពិសេសទៅទៀតនោះពួកគេហោះលឿនជាងខ្លា។ នាពេលមួយដែលខ្លាហោះដេញស្រីម្នាក់ដែលមានអាយុប្រហាក់ប្រហែលខ្លា ខ្លាពិតប្រឹងប្រែង តែខ្លាហោះចាប់នាងមិនបានទាល់តែសោះ ព្រោះតែនាងពូកែនិងចេះគេចបានរហ័ស។

ពេលដែលខ្លាទៅពួនវិញម្តង ខ្លាមិនដែលចេះទៅពួនឆ្ងាយឡើយ តែងតែទៅរកគម្ពោតព្រៃនៅជិតនោះឯង ហើយពួកគេពិតជាងាយស្រួលនិងរកឃើញខ្លាដែរ ដោយសារតែពួកគេបានឃើញភ្លើងពណ៌បៃតងខ្ចីនៃបេះដូងរបស់ខ្លានៅទីនោះ ហើយពិសេសពួកគេក៏ងាយនិងចាប់ខ្លាបានដែរ។

ពពួកខ្មោចតែងបានសើចឱ្យគ្នា នៅពេលមួយដែលគ្នាបានទៅពួននៅក្នុងគម្ពោតព្រៃហើយនៅពេលនោះគ្នាមិនអាចចេញទៅណាបានទេដោយសារតែគ្នាបានជាប់បន្លាយ៉ាងស្អិត។ រហូតដល់មានការជួយដោះពីពួកគេទើបគ្នាបានចេញរួចពីគម្ពោតព្រៃទាំងនោះ។

ពួកខ្មោចពិសេសខ្មោចនារីៗ កាលបើបានជួបគ្នាពេលខ្លះតែងបានសើចដាក់គ្នា ដោយហួសចិត្តថាគ្នាមិនសមណាមានរឿងបែបនោះសោះ។ត្រឹមត្រូវថាវាជារឿងអាម៉ាស់មួយដែរសំរាប់គ្នា។

សំរាប់ល្បែងទីពីរដែលពួកខ្មោចចូលចិត្តលេងដែរនោះ គឺការចង់បង្ហាញមុខមាត់ដ៏អាក្រក់គួរឱ្យខ្លាចទៅអ្នកដែលលេងជាមួយ។ ល្បែងនេះ ពួកអ្នកលេងទាំងអស់ត្រូវសំកាំងខ្លួននៅលើដើមឈើម្នាក់មួយៗ។ នៅចំណុចកណ្តាលនៃដើមឈើនោះ មានផ្លែព្រួញមួយដើម។ គេនិងចាប់ផ្តើមបង្វិលផ្លែព្រួញនោះ បើកាលណាមុខព្រួញចង្អុលទៅកាន់អ្នកណាហើយ អ្នកនោះនឹងត្រូវបង្ហាញរូបមុខខ្លាចផ្សេងៗទៅដល់អ្នកដទៃ។

គ្រប់ពេលដែលមានម្នាក់មកបង្ហាញមុខអាក្រក់របស់គេ ខ្មោចទាំងឡាយមិនខ្លាចអ្វីនេះទេ ពួកគេបែរទៅជាសើចសប្បាយទៅវិញដូចជាមានខ្មោចម្នាក់ក្រោយពីបានបង្វិលព្រួញហើយ ព្រួញនោះបានចង្អុលចំមុខ នាងបានហោះមកឈរចំកណ្តាលហ្វូងហើយបានបង្ហាញភាព អាក្រក់របស់នាង។នាងចាប់ផ្តើមហែកសំបកក្បាលរបស់នាងជាពីរដែលពេលនោះបានលេចចេញមកនូវលលាក្បាលសុទ្ធតែសសៃស្រវេមស្រវាមពេញតែសន្ទះក្បាល ឡើងពណ៌ក្រហមឆេះ។

គ្រប់ខ្មោចឯទៀតកាលបើបានឃើញរូបនេះហើយ ពួកគេបែរជានាំគ្នាសើចសប្បាយហាក់បីដូចជាមាននរណាម្នាក់បាននិយាយរឿងកំប្លែងប្រាប់ទៅពួកគេឥចឹង។ ចំណែកគ្នាវិញមិនបានសើចនិងគេទេ ហើយបានស្រម៉ៃថាប្រសិនបើមានមនុស្សលោកបាន ឃើញវិញនោះ តើពួកគេនឹងខ្លាចលស់ព្រលឹងយ៉ាងណា? ពិតណាស់ដែលគ្នាធ្លាប់តែឃើញ ក្នុងខ្សែរភាពយន្តតែពេលនេះវាពិតជាកើតឡើងនៅនិងកែវភ្នែករបស់គ្នាមែន។ ក្រៅពីនេះមាន ខ្មោចខ្លះ គេបានខ្វេះកែវភ្នែករបស់គេទាំងពីរ ដោយនៅពេលដែលកំពុងខ្វេះនោះមានឈាម បាញ់ចេញមកក្រៅស្ទើរកន្ទះម៉ែត្រ។ គេមិនមានការឈឺចាប់ទេតែគេបែរជាយកភ្នែកទាំងនោះ យកមកគ្រេះលេងដូចជាសីទៅវិញ។ ខ្លះទៀតហែកមាត់របស់គេឱ្យធំប៉ុនថាស។ ពួកគេបានធ្វើអ្វីៗ គ្រប់បែបយ៉ាង នៅពេល





ដែលព្រួញបានចង្អុលមកចំពួកគេ។

ចំណែកគ្នាវិញ គ្នាមិនចេះធ្វើមុខមាត់អាក្រក់ដូចពួកគេទេ ព្រោះតែគ្នាមិនចេះ។ មានពេលមួយមកដល់នៅពេលដែលព្រួញបានចង្អុលចំទិសរបស់គ្នា គ្នាបានបណ្តែតខ្លួនមកចំនុចកណ្តាលនៃវង់ល្បែង។ មានខ្មោចប្រមាណជាម្ភៃនាក់ដែលកំពុងសំកាំងខ្លួនហើយចង់ឃើញការបង្ហាញមុខរបស់គ្នា។ ពួកគេបានសំលឹងមកមើលគ្នាយ៉ាងស្ងៀមស្ងាត់ ឯគ្នាវិញក៏បានមើលទៅពួកគេវិញដែរ។ គ្នាខំរកនឹកថាតើត្រូវធ្វើអ្វីឱ្យពួកគេខ្លាចមិនសើចចំអកឱ្យគ្នាបានទៀត។ នឹកអ្វីមិនឃើញនឹកអ្វីក៏មិនចេញ គ្នាក៏នៅសំកាំងខ្លួនស្ងៀមធ្វើទឹកមុខស្មើហើយបានស្រែកបើកមាត់ បើកភ្នែកបង្ហាញធ្មេញនិងហែកត្រចៀកព្រមទាំងស្រែកថា៖

«អ្ហ៎ៗៗៗៗៗៗ»

ពួកខ្មោចកាលបើបានលឺសំលេងនេះភ្លាមគ្មានអ្នកណាសើចគ្មានអ្នកណាមើលគ្នាទៀតទេពួកគេបាននាំគ្នាហោះដូចជាព្រួញចូលទៅផ្ទះរបស់ពួកគេរៀងៗខ្លួនបាត់អស់។

គ្នាហួសចិត្តខ្លួនឯងព្រោះតែ គ្នាមិនបានបង្ហាញមុខមាត់អាក្រក់ផង តែបែរជាអាចបន្លាចពួកគេទៅវិញ។ ឃើញដូចនេះគ្នាបានសំកាំងខ្លួនញញឹមឱពព្រឹមនៅកណ្តាលដើមឈើរ ហើយស្រែកប្រាប់ឱទៅពួកគេថា៖

**«ម៉េចខ្លាចឬទេ?មកៗលេងវិញខ្ញុំលែងធ្វើទៀតហើយ»**

ក្រោយពីមានកាបញ្ជាក់ដូចនេះ មានខ្មោចខ្លះបានដើបអើតកចេញពីផ្ទះមួយៗមកវិញហើយខំសំលឹងមកមើលគ្នាដោយសេចក្តីញញើត។ ពួកគេនៅតែមិនទាន់ចង់ចេញរហូតដល់តែគ្នាបានបញ្ជាក់ពីរបីផងទើបពួកគេចេញមកបង្ហាញខ្លួនម្តងមួយៗ ហើយមានខ្មោចស្រីចំណាស់ម្នាក់បាននិយាយថា៖

**«អូ្វយពូកាពិតជាពូកែធ្វើឱពួកយើងខ្លាចមែន!»**

គ្នាបានញញឹមគ្រវីក្បាលហើយតបទៅវិញថា៖

**«កុំខឹងទៅ! ខ្ញុំឈប់ធ្វើឥចឹងទៀតហើយ!»**

ពួកខ្មោចទាំងអស់បាននាំគ្នាសើចគ្រប់ៗគ្នាឡើងរំពងអាកាសនៅពេលដែលបានលឺគ្នានិយាយដូចនេះ។

ខ្លាអស់សំណើចនៅក្នុងចិត្តតែម្នាក់ឯង នៅពេលបានដឹងថាសូម្បីតែក្លាយខ្លួនទៅជាខ្មោចក៏ចេះខ្លាចដែរចុះទំរាំទៅមនុស្សនោះ តើពួកគេនឹងខ្លាចពពួកខ្មោចយ៉ាងណាទៅ? អ្វីដែលខ្លាបានឆ្ងល់ជាងគេនៅត្រង់ថានៅពេលដែលគេធ្វើមុខមាត់អាក្រក់ ពួកខ្មោចទៅជាសើចសប្បាយ តែនៅពេលដែលខ្លាបានបង្ហាញមុខមាត់ជាមនុស្សធម្មតាសោះ ពួកគេបែរជាខ្លាចទៅវិញ។ ខ្លាបានគិតនិងស្មានថាប្រហែលជាមនុស្សក៏ខ្លាចខ្មោច ឯខ្មោចវិញសោតក៏ខ្លាចនិងការស្រែករបស់មនុស្សលោកវិញដែរ។

ទោះយ៉ាងណាក៏ដោយទាំងនេះគ្រាន់តែជាការស្រម៉ៃរបស់ខ្លាតែប៉ុណ្ណោះ ព្រោះតែខ្លានៅមិនទាន់ដឹងច្បាស់ ដោយសារតែខ្លាទើបតែនិងមក មិនដូចជាពួកគេដែលបានមកតាំងសមាធិខ្លះដល់ជិតមួយរយថ្ងៃ ខ្លះទៀតមួយឆ្នាំហើយក៏មានអ្នកខ្លះទៀតលើសពីមួយឆ្នាំផងដែរ ដោយសារតែពួកគេនៅមិនទាន់ចង់ទៅចាប់ជាតិថ្មី។ ពួកគេប្រហែលជាយល់ថានៅទីវត្តនោះសប្បាយ ឬក៏មានខ្លះមិនចង់ទៅចោលសង្សារថ្មីថ្មោងរបស់ពួកគេ ដែលទើបនិងស្គាល់នៅក្រោយការស្លាប់នោះក៏មិនដឹង។

ជាការពិតណាស់នៅក្នុងចំណោមខ្មោចស្ទើរតែទាំងអស់ដែលរស់នៅក្នុងវត្តសុភាឃួន មិនមានអ្នកណាមួយកាចសាហាវឬក៏ទៅលេងបន្ទាចដល់មនុស្សលោកនោះទេ។

ពួកគេគឺជាខ្មោចសុភាពរាបសារ ចូលចិត្តរាប់អានគ្នាណាស់ ហើយពួកគេក៏មិនដែលមានជំលោះនិងគ្នាដែរ។ពួកគេនាំគ្នាលេង នាំគ្នាទន្និញធម៌យ៉ាងសុខសាន្ត។

មានពេលមួយ បើចាន់ណារិនឯងបានមកមើលឯងលេង មិនដឹងថាចាន់ណារិនឯងសប្បាយយ៉ាងណានោះទេ? នៅពេលនោះមានក្រុមកីឡាពីរក្រុម គឺពួកខ្លាមួយក្រុមដែលគេហៅថាក្រុមសុភាឃួន ឯក្រុមមួយទៀតគឺក្រុមព្រះពុទ្ធ ដែលក្រុមនោះបានមកពីវត្តព្រះពុទ្ធ ឬនិយាយម្យ៉ាងទៀតអ្នកដែលបានបូជានៅទីនោះ។

កាលនោះវាពិតជាសប្បាយណាស់ ពពួកខ្មោចដែលនៅតាំងសមាធិជាច្រើនរយនាក់នៅក្នុងវត្តរបស់ពួកយើងនិងពពួកខ្មោចនៅឯវត្តព្រះពុទ្ធ បាននាំគ្នាទៅចូលរួមការប្រកួតរបស់ពួកយើងដែលនាំគ្នាលេងនៅឯពហុកីឡាដ្ឋានជាតិអូឡាំពិក។ អ្នកគាំទ្ររបស់ក្រុមខ្លា មិនសូវជាមានគ្នា





ច្រើនទេ មានប្រមាណជា២០០នាក់ប៉ុណ្ណោះ តែសំរាប់ពួកអ្នកគាំទ្រខាងក្រុមកីឡាវត្តព្រះពុទ្ធវិញ ចាន់ណារិនអើយ! ខ្លាពិតជារាប់មិនបានទេ ពួកគេមានគ្នា ឡើងខាប់ទឹកខាប់ដីស្ទើរតែមួយចំហៀងកន្លះស្តាតទៅហើយ។

ពួកគេរួមមានក្មេង មានចាស់មានស្រីមានប្រុស ពោះម៉ាយមេម៉ាយ ក្រមុំកំលោះ។ ទោះបីបើពួកគេមានអាយុភេទនិងការស្លាប់ខុសៗគ្នា តែពួកគេបានមកដើម្បីលើកទឹកចិត្តឲក្រុម របស់ពួកគេ។ចំណែកឯអ្នកគាំទ្ររបស់ក្រុមខ្លាវិញមានគ្នាតែមួយក្តាប់ប៉ុណ្ណោះតែទោះយ៉ាងណាអ្នកកីឡាយើងមិនបានបាក់ទឹកចិត្តទេហើយបានប្រឹងប្រែងលេងយ៉ាងស្វិតស្វាញ។

តាមពិតល្បែងនោះគ្មានអ្វីពិបាកទេ យើងមានអាញ្ញាកណ្តាលពីរនាក់ដែលពួកគាត់មានអាយុប្រហាក់ប្រហែលជា៤០ឆ្នាំ។ ពួកគាត់មកពីវត្តលង្កា ហើយបានមកចូលរួមជាអាញ្ញាកណ្តាលឲពួកយើងទាំងពីរក្រុម។ ល្បែងនេះលេងគ្មានចំណេញផលអ្វីទេ ពួកយើងលេងគ្រាន់តែដើម្បីមិត្តភាពតែប៉ុណ្ណោះ។ ពួកយើងចាប់លេងតាំងពីម៉ោងមួយព្រឹករហូតដល់ម៉ោងបីភ្លឺ។ ក្បួនច្បាប់នៃការលេងគឺពួកយើងត្រូវយកកែវភ្នែករបស់អាញ្ញាកណ្តាល ម្នាក់ម្ខាងៗ ដោយយកមកធ្វើជំនួសជាបាល់ដែលក្រុមមួយត្រូវដណ្តើមគ្នាយកមកគុបឲចូលតារាងនៃក្រុមមួយផ្សេងទៀត។ ការប្រកួតទាំងនេះវាមិនខុសពីការប្រកួតបាល់ទាត់ប៉ុន្មានឡើយតែគ្រាន់ថាតារាងរបស់យើងតូចមានរាងមូលដូចជាកង់ឡានកាំម៉ាស់ ឯការលេងនោះសោត យើងមិនលេងនៅលើដីនោះទេគឺយើងលេងនៅលើអាកាស ម្នាក់ៗត្រូវហោះដណ្តើមកែវភ្នែកពីគ្នាហើយគុបឲចូលគោលដៅ។ កាលនោះវាជាលើកទីមួយរបស់ខ្លាដែលបានចូលប្រកួត គេមិនទុកចិត្តឲខ្លាឡើងគុបនោះទេ គេបានចាត់ឲខ្លាជាអ្នកចាំហ្គូន។ហើយ៩នាក់ទៀតឡើងទៅស៊ុតជួរមុខ។

ការប្រកួតបានចាប់ផ្តើមឡើង នៅវេលាតាមកាលកំណត់ នៅក្រោយពីការប្រកាសតាមរយៈសំលេងកញ្ចែរបស់អាញ្ញាកណ្តាលដែលមានតែភ្នែកតែម្ខាងក្នុងការត្រួតពិនិត្យការប្រកួត។ វាពិតជាគួរឲសប្បាយណាស់។ ម្នាក់ៗបានហោះហើរគប់គ្រាប់ភ្នែក ប្តូរគ្នាពីរម្នាក់ទៅម្នាក់ដើម្បីបោះឲចំគោលដៅ។

ពួកអ្នកគាំទ្រខាងវត្តព្រះពុទ្ធពិតជាអស្ចារ្យណាស់ពេលដែលចាប់ផ្តើមលេងដំបូង។ ពួកគេបានស្រែកច្រៀងលើកទឹកចិត្តក្រុមរបស់គេដោយច្រៀងខ្លាំងៗថា៖

**«ព្រះពុទ្ធអ្នកមានបុណ្យ!!! សុភាឃ្នួនអ្នកមានកម្ម!!!»**

ពួកគេបានច្រៀងហើយច្រៀងទៀតរួមជាមួយសំលេងហ៊ូរយ៉ាងខ្លាំង។

ចំណែកឯអ្នកគាំទ្ររបស់ពួកគ្នាវិញនេះម្តង កាលបើបានលឺសំលេងសើចចំអកនេះហើយ ពួកគេតាំងច្រៀងតបទៅវិញម្នាក់ម្តងៗវិញថា៖

**«វត្តព្រះពុទ្ធអ្នកក្រ!!! វត្តសុភាឃ្នួនអ្នកមាន!!!»**

កាលបើពួកអ្នកគាំទ្រច្រៀងផ្ដីផ្ដងគ្នាដូចនេះ វាបានធ្វើឲបរិកាសកាន់តែអឹកធឹកយ៉ាងខ្លាំង ឯអ្នកលេងវិញ ក៏កាន់តែលេងយ៉ាងស្វាហាប់ណាស់ដែរ។ ពួកយើងបានហោះទង្គិចគ្នា បំណងតែដណ្តើមកែវភ្នែកមកតែក្រុមរៀងៗខ្លួន។នៅពេលនោះគ្នាសើចតែរហូតព្រោះមិននឹកស្មានថានៅទីនោះសប្បាយដល់ម្លឹង ពិសេសនៅ ពេលដែលបានច្រៀងឆ្លើយឆ្លងគ្នា។ កំពុងតែសប្បាយរីករាយនៅទិដ្ឋភាពនៅជុំវិញខ្លួនគ្រាប់ភ្នែកដែលគប់ដោយក្រុមកីឡាវត្តព្រះពុទ្ធបានចូលផ្ទុកនៅចំហៀងកខាងស្តាំរបស់គ្នា។នៅពេលនោះហើយដែលសំលេងសប្បាយរបស់ក្រុមអ្នកគាំទ្រវត្តព្រះពុទ្ធកាន់តែបំពងសំលេង ដែលវាផ្ទុយស្រឡះសំរាប់ពួកគ្នាដែលនាំគ្នានៅស្ងៀមមិនមាត់មិនក។ពួកអ្នកមកពីវត្តព្រះពុទ្ធពិតជាមានការសប្បាយរីករាយណាស់នៅពេលដែលគ្នារបស់គេបានគុបចូលដូចនេះ។ ឯមេក្រុមរបស់ គ្នាវិញមើលមក គ្នាទាំងទឹកមុខហួសចិត្ត។ ការលេងបានបន្តទៅទៀត។នៅតាមការសង្កេតរបស់គ្នាពួកខ្មោចវត្តព្រះពុទ្ធពិតជាខ្លាំង ពួកគេមានមាឌធំៗ ជាងពួកយើង ហើយពិសេសមុខមាត់របស់ពួកគេមាំៗ មើលទៅគួរឲខ្លាច។ នៅពេលដែលគេគប់ប៉ះទៅឲគ្នាគេម្តងៗ ពួកគេទាំងនោះពិតជាមានការស្ទាត់ជំនាញណាស់ ហើយគុបក៏មិនដែលឲផុតពីដៃគ្នារបស់គេដែរ។ ចំណែកឯពួកយើងវិញ ចូលចិត្តតែហោះទៅបុកពាំងនៅពេលដែលគ្រាប់ ប្រុងនិងចូលហ្លួនរបស់ពួកយើង។ ពេលដែលកំពុងតែហោះ ដណ្តើមគ្នាទៅវិញទៅមកនោះ គ្រាប់ភ្នែកបានមកដល់ដៃក្រុមរបស់ពួកយើងវិញម្តង។ ពួកយើងកាលបើបាននៅនិងដៃហើយ បានហោះគុបទៅឲគ្នាយើងម្នាក់ទៀតដែលនៅជិតៗគ្នារហូតដល់អ្នកចុងក្រោយដែលបានគុបយ៉ាងខ្លាំងបំរុងនិងទំលុះបង្គោលរបស់ក្រុមវត្តព្រះពុទ្ធ តែជាអកុសលកែវភ្នែកទាំងនោះបែរជាហោះទៅបុកបង្គោលភ្លើងទៅវិញ លាន់ស្នូរលឺផាំង។ ម្នាក់ៗដែលកំពុងទស្សនានាំគ្នាប្រហោងពោះគ្រប់គ្នា ហើយនៅពេលដែលពួកយើងគុបខុសដូចនេះ ពួកអ្នកគាំទ្រវត្តព្រះពុទ្ធ





កាន់តែហ៊ូរសប្បាយបន្តទៅទៀត។ ចំណែកឯអ្នកគាំទ្រយើងវិញគ្រវីក្បាលអស់សង្ឃឹម ឯអាញ្ញាកណ្តាលវិញបែរជាយកដៃមកខ្ទប់រន្ធភ្នែករបស់គាត់។ គ្នាមិនដឹងថាមានរឿងអ្វីទេ តែប្រហែលជាគាត់មានការឈឺចាប់ហើយមើលទៅ។ ការប្រកួតកាន់តែបន្តឯអ្នកគាំទ្រកាន់តែស្រែកច្រៀងមិនចេះហត់។

**«ព្រះពុទ្ធអ្នកមានបុណ្យ!!! សុភាឃ្នួនអ្នកមានកម្ម!!!»**

**«វត្តព្រះពុទ្ធអ្នកក្រ!!! សុភាឃ្នួនអ្នកមាន!!!»**

ចប់ការប្រកួតរយៈពេលពីរម៉ោង នៅទីបំផុតលទ្ធផលបានទៅដល់ក្រុមវត្តព្រះពុទ្ធ៨ទល់និង២។ ពួកអ្នកឈ្នះបានរីករាយនិងជោគជ័យនេះ តែអ្នកដែលចាញ់វិញក៏មិនកើតទុក្ខអ្វីដែរ។ ពួកយើងបានបំបែកផ្លូវគ្នាត្រលប់មកកាន់វត្តរៀងៗខ្លួន។

បីថ្ងៃគំរប់មុនរយៈមួយខែដែលគ្នាបានស្លាប់ បុទមវត្តីបានមកជួបគ្នា។ ពួកនាងទាំងពីរបានសួរសុខទុក្ខក្រែងគ្នាមានការលំបាកណាខ្លះ តែគ្នាបានប្រាប់ទៅពួកនាងវិញថា គ្នានៅទីនេះមានសេចក្តីសុខណាស់ ហើយគ្នាក៏ពុំមានការនឹករលឹកដល់ជីវិតជាតិមុនទៀតដែរ។ ពិសេសនោះក៏មិនបានទៅមើល ទៅលេងក្រុមគ្រួសារឲបានញឹកញាប់នោះទៀតដែរ។ ពួកនាងទាំងពីរកាលបើបានលឺពាក្យសំដីទាំងនេះ ពួកគេញញឹមដោយសេចក្តីសប្បាយរីករាយ ហើយពួកគេក៏បានប្រកាសប្រាប់មកគ្នាវិញថាគ្នាត្រូវត្រលប់ទៅជួបស្តេចយមរាជវិញដើម្បីកាត់សេចក្តីថា គ្នាត្រូវទៅបន្តនៅឯឋានណា? ពួកនាងបានបញ្ជាក់ថា គ្នាបានប្រព្រឹត្តិបានល្អ ទើបគ្នាអាចទៅបានមុនថ្ងៃកំណត់ដូចនេះ។

នៅពេលដែលបានដឹងពីដំណឹងនេះហើយ គ្នាមិនអរហើយក៏មិនសប្បាយដែរតែគ្នាហាក់មានសេចក្តីក្រៀមក្រំដែលគ្នាប្រញាប់អស់កម្មយ៉ាងលឿនដូចនេះ។ បីថ្ងៃចុងក្រោយនោះ គ្នាបានទៅលេងជាចុងក្រោយម្តងទៀតនូវក្រុមគ្រួសាររបស់គ្នា ដោយគ្នាបានថ្វាយបង្គំលាលោកអ្នកមានគុណទាំងពីរហើយនឹងសន្យាថានឹងតាមថែរក្សាពួកគាត់បន្ត។ ក្រៅពីនោះគ្នាបានទៅលេងសារ៉េតដែលកំពុងឈឺនៅឡើយគ្នាបានទៅលេងផងដែរសំលាញ់រ៉ូហើយបានប្រសិទ្ធិពរឲគេឆាប់បានចេញទៅប្រទេសជប៉ុនដែលគេបានប៉ងជាយូរណាស់មកហើយ។ គ្នាបានទៅមើលរិទ្ធី ភក្តី

ពិសេសគួរឲ្យណ្ដឹងកំសត់របស់ខ្ញុំផងដែរ។ មានតែចាន់ណារិនឯងប៉ុណ្ណោះដែលខ្ញុំមិនអាចទៅបានព្រោះពួកម៉ាកឯងនៅឆ្ងាយពេក តែខ្ញុំនៅតែមានបំណងក្នុងចិត្តថាត្រូវតែទៅប្រាប់ពួកម៉ាកឯងថាខ្ញុំនឹងទៅឋានណាទៀត។

ជាការពិតនៅពេលប៉ុន្មានថ្ងៃចុងក្រោយនោះបានធ្វើឲខ្ញុំមានការត្រៀមក្រំបន្តិចតែក្នុងចិត្តរបស់ខ្ញុំហាក់បានស្រឡះទាំងអស់នៅក្នុងបញ្ហាទាំងឡាយ បញ្ហាមនុស្សលោកពិសេសភាពខ្វល់ខ្វាយគ្រប់ជំពូក។

នៅយប់ចុងក្រោយ ខ្ញុំបានទៅលាមិត្តភក្តិខ្មោចដែលបានធ្លាប់លេងជាមួយខ្ញុំ ពិសេសក្រុមគប់គ្រាប់ភ្នែក។ ពួកគេពិតជាសប្បាយនៅពេលបានដឹងថាខ្ញុំបានចេញមុនពេលកំនត់ដូចនេះ ហើយគេក៏បានផ្ដាំឲខ្ញុំឧស្សាហ៍មកលេងពួកគេម្ដងៗផងបើអាចធ្វើទៅរួច។ ខ្ញុំញញឹមដោយសន្យាថានឹងធ្វើបើសិនជាអាច។

ពេលវេលាបានមកដល់ នៅរាត្រីដ៏ស្ងាត់ជ្រងំនៅក្នុងយប់ថ្ងៃ១២ឈានចូលថ្ងៃទី១៣នៃខែវិច្ឆិការ បុទមវត្ដីបានមកដល់ហើយប្រាប់មកខ្ញុំឲចាកចេញទៅជាមួយពួកនាង។ មុនពេលដែលចេញពីទីនោះ ខ្ញុំបានសុំនាងទាំងពីរឲជូនខ្ញុំទៅជួបចាន់ណារិនឯង តែត្រូវពួកនាងប្រកែក ព្រោះត្រូវទៅជួបស្ដេចយមរាជជាមុនសិនដោយមិនអាចអាក់ខានបានឡើយ។តែនាងបានបញ្ជាក់ឲខ្ញុំមានសង្ឃឹមថាក្រោយពីការកាត់សេចក្ដីហើយប្រហែលជាខ្ញុំអាចសុំទៅបាន។ក្រោយពីពួកនាងបានរៀបរាប់ពីមូលហេតុទាំងនេះហើយ ពួកយើងទាំងបីបានចេញដំណើរដោយបានហោះបណ្ដើរនិងសំលឹងទៅផ្នូររបស់ខ្ញុំបណ្ដើរជាផ្នូរដែលខ្ញុំបានតាំងសមាធិនិងបានរស់នៅទីនោះ ជាមួយនិងបណ្ដាខ្មោចឯទៀត។អ្វីដែលខ្ញុំនឹកក្នុងចិត្តនៅពេលនោះជាងគេគឺសាកសពខ្លួនប្រាណរបស់ខ្ញុំដែលមិនទាន់ទាំងរលាយអស់សាច់ផងខ្ញុំត្រូវបានចាកចេញពីគេទៅហើយ។ ខ្ញុំបានសំលឹងមើលទៅផ្នូររហូតដល់ខ្ញុំបានហោះចេញផុតពីកន្ទុយភ្នែក។

តែមួយប៉ប្រិចភ្នែកប៉ុណ្ណោះ ពួកខ្ញុំបានមកដល់ឋាននរកវិញម្ដងទៀត ស្របពេលជាមួយនិងខ្មោចបួននាក់ទៀតដែលរួចទោសដូចជាខ្ញុំដែរ។

ពួកយើងទាំងអស់ខ្ញុំបានក្រាបថ្វាយបង្គំស្ដេចយមរាជដូចជាទំលាប់ចាស់ ហើយនៅពេលនោះ





លោកឧបរាជដែលនៅឈរជាប់និងព្រះអង្គបានពោលឡើងថា៖

**«ពួកអ្នកទាំងអស់ខ្ញុំបានរួចផុតពីទោសអស់ហើយនូវបាបកម្មទាំងឡាយដែលពួកអ្នកបានសាងកាលនៅរស់ជាមនុស្សលោក នៅពេលនេះពួកអ្នកមានសិទ្ធដោយសេរីក្នុងការជ្រើសរើសដើម្បីបន្តដួងព្រលឹងរបស់អ្នកទៅកាន់ឋានថ្មី គឺមានឋានទាំងបី ឋានលើ ឋានកណ្ដាល ឋានក្រោមរបស់យើងនេះ»** លោកឧបរាជឈប់បន្តិចហើយបន្តទៀតថា៖

**«តើពួកអ្នកចង់ទៅឋានណា?»**

**«ខ្ញុំចង់ទៅកើតនៅឯឋានមនុស្សលោកវិញ»** ស្ត្រីម្នាក់បានឆ្លើយយ៉ាងប្រញាប់ដោយមិនស្ទាក់ស្ទើរបន្តិច ពួកយើងបានក្រលេកមើលទៅគាត់ គ្រប់គ្នាឯលោក ឧបរាជបានញញឹម ដោយងក់ក្បាលហើយនិយាយឡើងថា៖

**«អ្នកប្រហែលជាមិនទាន់បានស្រឡះនៅក្នុងចិត្តឬក៏ប្រហែលជាមិនទាន់បានយល់ច្បាស់ពីគម្ពីធម៌ដែលខ្ញុំបានឲយកទៅទន្និញហើយមើលទៅ!»**

ចំណែកឯពួកខ្ញុំទាំងបួននាក់ឯទៀតវិញបានមើលមុខគ្នាបន្តទៅវិញទៅមក នៅពេលដំណាលគ្នានោះដែរ ស្ដេចយមរាជ្យបានបន្ទូលឡើងថា៖

**«យើងត្រូវការអង្គរក្សពីរនាក់ឲមកជួយការពារយើង បើពួកអ្នកណាមានបំណងនៅទីនេះ យើងនឹងព្រមទទួល»**

គ្រាន់តែបានលឺប៉ុណ្ណេះ ខ្មោចពីរនាក់បានលើកដៃយ៉ាងរហ័សព្រមគ្នា ដើម្បីទទួលកិច្ចការ ទាំងនេះ។ នៅសល់តែខ្ញុំនិងលោកតាចំណាស់ម្នាក់ នៅមើលមុខគ្នាឡេងឡង់បន្ត។ លោកឧបរាជបានសួរបញ្ជាក់នៅពេលដែលយើងនៅមិនទាន់សំរេចចិត្តឡើងថា៖

**«តើពីរនាក់យើងវិញចង់ទៅណាដែរ?»** គាត់ឈប់បន្តិចហើយបន្តទៀតថា៖

**«យើងនៅទីនេះគ្មានសិទ្ធិបង្ខំពួកអ្នកឲទៅណាឡើយ ព្រោះតែពួកអ្នកមិននៅក្រោមការគ្រប់គ្រង់របស់ពួកយើងទេពួកអ្នកជាអ្នកដែលមានបុណ្យនិងត្រូវបានគេគោរពគ្រប់ឋានការទៅឋានណា គឺជាការសំរេចចិត្តរបស់ពួកអ្នក តែខ្ញុំសូមបញ្ជាក់ប្រាប់ថាទោះបើអ្នកទៅឋានណាក៏ពួកអ្នកនឹងមិនទៅពិបាកទៀតដែរ»**

ចប់សំដីខ្ញុំបានក្រលេកមើលទៅបុទមវត្ដីដែលញញឹមមិនដាច់ហើយខ្ញុំបាននិយាយឡើងថា៖

«ខ្ញុំព្រមទៅកាន់ឋានសួគ៌»

លោកតាចំណាស់កាលបើបានលឺពាក្យទាំងនេះគាត់ញញឹមមករកគ្នាហើយនិយាយឡើងដែរថា៖

«ខ្ញុំទៅដែរ!»

**«ល្អណាស់ឥចឹង ពួកអ្នកអាចចេញដំណើរបានហើយ»**

លោកឧបរាជបាននិយាយដោយចុះមកខាងក្រោម សំដៅមកពួកយើងរួមជាមួយនិងថាសមួយដែលមានគ្រាប់គុជបីគ្រាប់ដែលមានពន្លឺដ៏ចញ្ចាំងចិញ្ចាច។

លោកឧបរាជបានហុចមួយគ្រាប់ឱទៅកាន់ស្ត្រីដែលចង់ទៅកើតនៅឯឋានមនុស្សលោកវិញ។ នៅក្រោយពីស្ត្រីនោះបានលេបរួចហើយ រូបរាងរបស់គាត់បានរលាយមួយរំពេច ហើយទៅចាប់កំណើតជាមួយស្ត្រីម្នាក់ដែលរស់នៅក្នុងទីក្រុងភ្នំពេញ។ តាមអ្វីដែលយើងបានឃើញតាមរយៈកញ្ចក់ទិព្វរបស់ឋាននរក ស្ត្រីរូបនោះពិតជាគួរឱស្រលាញ់ណាស់នៅពេលដែលបានក្លាយខ្លួនទៅជាទារកហើយយំលឺសូរតែ «ង៉ាៗៗ» ពេញតែមន្ទីរពេទ្យ។ យើងក៏បានដឹងផងដែរថានាអនាគតកាល ទារកដ៏ស្រស់ខ្ចីនោះនឹងក្លាយទៅជាវិជ្ជបណ្ឌិតម្នាក់ដ៏ពូកែរសាកសិទ្ធទៅនិងជំងឺគ្រប់ប្រភេទហើយរូបនាងនេះហើយដែលនឹងត្រូវជួយយកអាសារដល់មនុស-រាប់ម៉ឺននាក់ឲ្យរួចផុតពីជំងឺទាំងឡាយ។ លើសពីនោះទៅទៀតនាងនឹងក្លាយទៅជាវិជ្ជបណ្ឌិតដ៏ល្បីល្បាយនៅក្នុងប្រទេសកម្ពុជានាដើមឆ្នាំ២០៤០ខាងមុខនេះ។ ចំណែកឯបុរសពីរនាក់ទៀតដែលចង់ក្លាយខ្លួនទៅជាអ្នកការពារស្តេចយមរាជនោះ ត្រូវបានលោកឧបរាជឱទៅជំរះខ្លួននៅក្នុងអាងទឹកពិសិទ្ធនៃឋាននរក។ ចំណែកឯលោកតាចំណាស់នោះ នៅក្រោយពីគាត់បានលេបគុជនោះ គាត់ក៏ត្រូវបានរលាយទៅកាន់ឋានសួគ៌ដែរ ដោយគាត់បានក្លាយទៅជាចាស់ទុំនៅឯឋានសួគ៌។

នៅសល់តែគ្នា ហើយនៅពេលដែលលោកឧបរាជបានហុចថ្នាំមកដល់ គ្នាបានសួរលោកថា៖

**«ពេលដែលខ្ញុំលេបហើយតើបុទមវត្តី ពួកនាងនិងទៅតាមខ្ញុំយ៉ាងម៉េច?»**

**«ដូចជាអ្នកដឹងហើយ ពួកនាងជាភរិយាយរបស់អ្នកតាំងតែពី៥០០ឆ្នាំមុនមកម្លេះ ហើយពិសេសនោះទៀតពួកនាងបាននៅរងចាំអ្នកតាំងពីរាប់ឆ្នាំណាស់ទៅហើយ ដូចនេះមិនថាអ្នកទៅណានោះទេ ពួកនាងនឹងទៅតាមបំរើអ្នកជាប់ជានិច្ច ព្រោះតែពួកអ្នកបានសន្យារស់នៅជាមួយគ្នាជាអមតៈ»** ចប់សំដីរបស់លោកឧបរាជ បុទមវត្តីបានងក់ក្បាលទទួលស្គាល់ថាវាជាការពិតនូវអ្វីដែលលោកឧបរាជបាននិយាយប្រាប់។

គ្នាបានយកគុជនោះមកដាក់នៅនិងមាត់បំរុងនឹងលេបវាចូលទៅហើយ តែគ្នាបានដកវាចេញមកវិញហើយសួរទៅលោកឧបរាជបន្តទៀតថា៖

**«លោកឧបរាជ ខ្ញុំសូមអង្វរ តើលោកមេត្តាអនុញ្ញាតឲខ្ញុំបានទៅលេងមិត្តភក្តិខ្ញុំម្នាក់ ដែលនៅស្រុកបារាំងដើម្បីប្រាប់ពីដំណើររបស់ខ្ញុំទៅឋានថ្មីបានដែរឬទេ?»**

លោកឧបរាជមិននិយាយស្តីតែបែរជាសំលឹងទៅមើលព្រះភ័ក្ររបស់ស្តេចយមរាជ ព្រះអង្គដែលមានវត្តមាននៅទីនោះដែរ បានងក់ព្រះកេសដោយសេចក្តីករុណាដោយយល់ព្រមឱគ្នាបាន មកជួបចាន់ណារិនឯងមុនពេលដែលគ្នាឆ្ពោះទៅកាន់ភពថ្មី។ព្រះអង្គបានមានបន្ទូលផងដែរថា៖

**«ក្រោយពីអ្នកបានទៅប្រាប់គេហើយ ត្រូវលេបថ្នាំនោះភ្លាមដើម្បីទៅកាន់ភពថ្មីជាប្រញាប់ មិនត្រូវរុញរាឡើយបើមិនដូចនោះទេ អ្នកនឹងក្លាយទៅជាព្រលឹងគ្មានព្រំដែនមិនខាន។»**

គ្នាបានទទួលពាក្យរបស់ព្រះអង្គដោយសេចក្តីត្រេកអរជាពន់ពេក ហើយបានសំដែងអំណរគុណដ៏ជ្រៀលជ្រៅចំពោះព្រះអង្គនិងលោកឧបរាជដែលបានអនុញ្ញាតដូចនេះ។ រួចហើយទើបគ្នាបានថ្វាយបង្គំលាចេញមកកាន់ស្រុកបារាំងភ្លាម។ នៅពេលនោះគ្នាបានទុកគ្រាប់គុជនៅនឹងភរិយារបស់គ្នាទាំងពីរ។

គ្នាបានមកដល់ស្រុកបារាំងត្រូវនឹងយប់១៣ខែវិច្ឆិការឆ្នាំ២០០៣។ គ្នាពិតជាសប្បាយចិត្តណាស់ពេលដែលបានឃើញចាន់ណារិនឯងកំពុងតែដេកយ៉ាងស្កប់ស្កល់នៅលើគ្រែ ហើយពិសេសនោះធ្វើឱគ្នាអស់សំណើចនៅពេលដែលឃើញពួកម៉ាកឯងដេកចំទិតគូទ។ បុទមវត្តី ពីរនាក់គេមិនបាននៅជិតគ្នាទេ ពួកគេបែរមុខចេញដោយគ្រវីក្បាលគួរឱស្រលាញ់។ គ្នាបាននិយាយទៅកាន់ពួកនាងថា

**«ចាន់ណារិនឯងមិនដែលចោលទំលាប់ចាស់នោះទេ»** ពួកយើងបាននាំគ្នាសើចព្រមៗគ្នា។ នៅពេលនោះដែរ គ្នាបានអញ្ជើញដួងព្រលឹងរបស់ចាន់ណារិនឯងឱមកជួបគ្នា។ គ្នាមិនដឹង

ទេថា ចាន់ណារិនឯងនៅមាន ចាំដែរឬទេ? នៅពេលដែលគ្នាបានពន្យោសប្តិដល់ពួកម៉ាកឯង ពួកម៉ាកឯងពិតជាមានការភ្ញាក់ផ្អើលព្រោះធ្លាប់តែឃើញគ្នាពេលកន្លងមានទឹកមុខស្រពោន តែពេលនេះគ្នាបែរជាមានទឹកមុខស្រស់បស់ទៅវិញ មូលហេតុគឺទីមួយគ្នាបាន ឃើញចាន់ណារិនឯងដេកចំទិតគូទ ហើយទីពីរគឺគ្នាបានជួបចាន់ណារិនឯងជាលើកចុងក្រោយ មុនពេលដែលគ្នាចេញទៅកាន់ភពថ្មីមួយទៀត។

នៅក្នុងសុបិន្តនោះ គ្នាបាននិយាយសើចៗ ចាន់ណារិនឯងបានសួរមកគ្នាថាស្រីៗពីរនាក់នោះជាអ្នកណា? តាមពិតទៅពីរអ្នកនឹងហើយគឺជាបុទមវត្តី ជាភរិយារបស់គ្នាតាំងពីអឌិតជាតិ។ តែកុំទាន់ប្រាប់ដានិតវើយ ប្រយ័ត្ននាងអន់ចិត្ត។

នៅយប់នោះដែរ គ្នាបានប្រាប់ទៅពួកម៉ាកឯងថា គ្នាបានចប់កម្មពារអស់ហើយ. ឥឡូវនេះគ្នាត្រូវទៅកាន់កន្លែងថ្មី នៅពេលនោះគ្នាក៏បានប្រាប់ចាន់ណារិនឯងផងដែរថា ត្រូវប្រាប់មិត្ត ភក្តិយើងទាំងអស់ឱនាំគ្នាសាងតែអំពើរល្អ កុំប្រព្រឹត្តិអំពើរបាបឱសោះ។

តើពាក្យសំដីទាំងនេះចាន់ណារិនឯងមាននៅចាំដែរឬទេ?

នៅយប់នោះ ពីរនាក់យើងបានប្រលែងគ្នាលេងយ៉ាងសប្បាយ តែនៅពេលវេលាភ្លឺជិតមកដល់ គ្នាក៏ត្រូវចាកចេញពីពួកម៉ាកឯងដែរ។

នៅរាត្រីនោះគ្នាពិតជារីករាយដែលបាននៅលេងជាមួយពួកម៉ាកឯងហើយគ្នាក៏បានដឹងដែរថា ពួកម៉ាកឯងមានការក្រៀមក្រំនៅពេលដែលគ្នាត្រូវឃ្លាតចេញមកកាន់ភពថ្មីយ៉ាងនេះ។

## ទំព័រនៃភពថ្មី

គ្នាបានមកដល់ភពថ្មីនៅក្រោយពេលពីបានលេបគុជរបស់លោកឧបរាជរួចមក។ មកដល់ទីនោះ គ្នាព្រមទាំងបុទមវត្តីបានទទួលដោយទេវតាការងារម្នាក់នៅឯដើមស្ពានមាសចូលមកកាន់ឋានសួគ៌។ ពួកយើងទាំងបីបានមកតាមព្រះអង្គដោយស្នាមញញឹមមិនដាច់ មកកាន់វិមានមួយដ៏ធំស្កឹមស្កៃដែលនៅទីនោះទេវតាការងារ បានពន្យល់ភារកិច្ចដែលគ្នាត្រូវទទួល។ នៅក្នុងវិមានដែលមានពណ៌មាសដ៏ចិញ្ចាចរបស់ពួកយើង ទេវតាការងារ បានពន្យល់ពីរការប្រើប្រាស់របស់





របរនៅក្នុងវិមានថ្មីរបស់ពួកយើង លើសពីនេះទៀតព្រះអង្គបានចាត់ឱគ្នាក្លាយនៅជាផ្កូងតារាឯកមួយអង្គដែលមានភារកិច្ចទទួលការពារព្រះអង្គច័ន្ទនៅពេលដែលលោកចេញទៅបំភ្លឺលោកម្តងៗ។

បុទមវត្តី កាលបើដឹងថាគ្នាបានទទួលការងារថ្មីនេះ នាងទាំងពីរមានសេចក្តីរីករាយជាពន់ពេក។ ពួកយើងមិនដឹងនិយាយយ៉ាងម៉េចដើម្បីពិពណ៌នាការសប្បាយពេញចិត្តរបស់យើងទាំងនេះទេ។ នៅពេលដំបូងនៃការមកដល់ភពថ្មី ពួកយើងទាំងបីមិនដែលចេញទៅណាមកណាទេ។ ពួកយើងនៅតែក្នុងវិមាន លុះដល់លោកប្រធានក្រុមមកប្រាប់ថា ត្រូវចេញដំណើរទៅការពារព្រះអង្គច័ន្ទពេលណានោះទើបបានគ្នាចេញមកក្រៅ។ ជាការពិតណាស់ ឋានសួគ៌គឺជាឋានដែលមនុស្សលោកទាំងពួងនៅក្នុងចក្រវាឡនេះតែងតែប្រាថ្នាចង់បានមករស់នៅទីនេះ។ គឺជាឋាននៃសេចក្តីសុខ ជាឋានដែលគ្មានការស្លាប់ ការច្រណែន ការឈ្លានីស ការព្យាបាទ និងអំពើរអាក្រក់ទាំងអស់។គោលដៅសំខាន់សំរាប់ហ្វូងទេវតាហ្វូងតារាទាំងឡាយនៅទីនេះគឺធ្វើការគ្រាន់តែសំរាប់ជួយចំលងមនុស្សលោកទាំងអស់ឱ្យរួចផុតពីសេចក្តីទុក្ខទោសទាំងពួងនិងជួយជាអ្វីដែលជាការខ្វះខាតរបស់មនុស្សដូចជាព្រះអាទិត្យ ព្រះច័ន្ទ ព្រះគង្គារ ព្រះពាយ ព្រះរុក្ខាជាដើម។ ព្រះទាំងនេះគឺសុទ្ធតែបំរើនូវសេចក្តីខ្វះខាតរបស់មនុស្សលោកទាំងអស់។ បើតាមតែគ្នាបានប្រមើមើលទៅឃើញថា នៅក្នុងផែនដីយើងនេះនៅមានមនុស្សលោកដែលមានកម្មច្រើនណាស់ ហើយបើពួកគេនៅតែមិនដឹងខ្លួនសាងអំពើល្អនោះទេ ពួកគេក៏នៅតែទទួលទារុណកម្ម ហើយពិសេសនោះក៏និងមិនអាចមកដល់ទីនេះបានដែរ។

នៅក្នុងឋានសួគ៌មិនមានអាគាររញ៉េរញ៉ៃដូចជានៅទីក្រុងភ្នំពេញនោះទេ គ្រប់ទេវតានិងតារាសុទ្ធតែមានវិមានរៀងៗខ្លួន។ គ្រប់គ្នាមិនត្រូវការបរិភោគអ្វីទាំងអស់តែម្នាក់ៗមិនទំនេរនោះទេ។ ពួកគេធ្វើការទៅតាមការចាត់តាំងរបស់ទេវតាការងារ។ ពេលដំបូងដែលគ្នាបានមកដល់គ្នាមិនដែលបានឃើញមុខព្រះអង្គច័ន្ទយ៉ាងដូចម្តេចនោះទេ គ្នាគ្រាន់តែបានដឹងថាព្រះអង្គជាបុត្ររបស់ព្រះឥន្ទតែប៉ុណ្ណោះ។

គ្នានិយាយប្រាប់ពួកម៉ាកឯងតាមត្រង់ទៅចុះ នៅពេលដែលគ្នាបានឃើញព្រះនាងដោយផ្ទាល់

ភ្នែក ព្រះនាងច័ន្ទពិតជាមានសំរស់ដ៏ត្រកាល ជាព្រះដែលស្អាតសុភាពរាបសារជាងគេនៅក្នុងឋានសួគ៌យើងនេះ។ ព្រះនាងពិតជាមានមន្តស្នេហ៍ណាស់ ទាំងដំណើរនិងព្រះសុរ្ណី។ ថ្ពាល់របស់ព្រះនាងមានពណ៌ដូចជាពងមាន់ឯម្រាមដៃវិញដូចជាបន្លាក្រូច។

គ្នាបានគិតថានៅក្នុងចក្រវាឡ ប្រហែលជាគ្មានអ្នកណាស្រស់ស្អាតជាងព្រះនាងឡើយ។ គ្រប់ពេលដែលគ្នាបាននិយាយសរសើរពីព្រះនាង ភ្លៅរបស់គ្នាបានជាំអស់ហើយដោយសារតែការក្តិចរបស់បុទមវត្តី។ ដោយសារតែផលបុណ្យកុសលពីជាតិជាមនុស្សដែលគ្នាបានសាង គ្នាត្រូវបានព្រះនាងច័ន្ទលើកគ្នាឲក្លាយទៅជាសេនាដៃស្តាំរបស់ព្រះនាង។ នាពេលដំបូងពេលដែលគ្នាចេញទៅបំពេញការងារជាមួយព្រះនាង នៅឯឋានមនុស្សលោកគ្នាពិតជារំភើបជាពន់ពេកនៅពេលដែលបានឃើញភពផែនដីសារជាថ្មី ហើយពិសេសនោះនៅពេលដែលបានឃើញមនុស្សលោកទាំងពួង ព្រមទាំងឪពុកម្តាយបងប្អូនញាត្តិមិត្តទាំងឡាយកំពុងតែនៅក្នុងគេហដ្ឋានហើយសំលឹងមករកពួកគ្នាដែលនៅកំពុងតែហែរហមព្រះនាងច័ន្ទបំភ្លឺលោកា។ ហ្វូងតារាដែលការពារព្រះនាងមានរាប់រយអង្គនៅពេលយាងទៅបំភ្លឺទ្វីបលោកម្តងៗ តែសំរាប់គ្នាពិតជាមានសំណាងដែលបាននៅជិតព្រះនាងជាងគេក្នុងចំណោមហ្វូងតារាទាំងអស់។ គ្នាប្រាប់ពួកម៉ាកឯងឲដឹងទៅចុះ នៅពេលដែលមានដួងព្រះច័ន្ទរះនៅលើផែនដី កាលណាពួកម៉ាកឯងបានឃើញតារាមួយអង្គដែលភ្លឺជាងគេនៅជិតជាងគេទៅនិងព្រះច័ន្ទ តារានោះហើយគឺជារូបគ្នាដែលកំពុងតែញញឹម និងសេចក្តីនឹករលឹកបំផុតមកដល់ពួកយើងទាំងអស់គ្នា និងកំពុងតែបន់ស្រន់ឲគ្រប់គ្នាសាងតែអំពើល្អ។ ពួកគ្នាត្រូវនៅទីនោះកំដរនិងការពារព្រះច័ន្ទពេញមួយរាត្រីរហូតដល់ភ្លឺ ដល់ពេលដែល ព្រះអាទិត្យដែលជាព្រះរាមរបស់ព្រះនាង មកទទួលវេនជំនួសទើបពួកគ្នាបានត្រលប់ទៅសំរាកនៅឯឋានសួគ៌វិញ។

អ្វីដែលគ្នាចង់ប្រាប់ពួកម៉ាកឯងមួយទៀត គឺនៅពេលដែលមិនមានព្រះច័ន្ទទៅបំភ្លឺទ្វីបលោក គឺដោយសារតែព្រះនាងត្រូវទៅគាល់ព្រឥន្ទដែលជាព្រះបិតារបស់ព្រះនាង។ ដឹងទេថាព្រះឥន្ទពិតជាស្រលាញ់ណាស់ព្រះរាជ្យបុត្រីរបស់ព្រះអង្គ។

ពួកម៉ាកឯងដឹងទេថា ហេតុអ្វីបានជាគ្នាអាចសរសេរសំបុត្រទៅពួកម៉ាកឯងបាន? តាមការពិតទៅ មានពេលមួយគ្នាបានសុំទៅលោកប្រធានក្រុមរបស់គ្នា ថាចង់សរសេរសំបុត្ររៀបរាប់ពី





រឿងទាំងឡាយដែលបានកើតឡើងទៅប្រាប់ពួកម៉ាកឯង តែគាត់មិនហ៊ានអះអាងសំរេចចិត្តបានទេ ឯព្រះច័ន្ទដែលជាប្រធានធំដែរនោះក៏មិនហ៊ានអារកាត់អ្វីដែរ។ នៅទីបំផុតសំណើរនេះត្រូវបានបញ្ជូនដល់ព្រះឥន្ទដែលធ្វើឲគ្នាស្ទើរតែធ្លាក់ថ្លើម។តែទោះយ៉ាងណាក៏ដោយព្រះអង្គពិតជាមានធម៌ករុណាហើយអនុញ្ញាតឲគ្នាបានសរសេរទៅយ៉ាងដូចនេះ។

ហ៊ឹម!! គ្នាដូចជាសរសេរយូណាស់ដែរហើយ មិនដឹងថាពួកម៉ាកឯងធុញទ្រាន់និងអានសំបុត្រគ្នាដែរឬទេ? ឥចឹងប៉ុណ្ណឹងចុះកុំឲពួកម៉ាកឯងហត់ខ្វាំងពេក។ អូ!៖ គ្នាមានរឿងមួយទៀតដែលគ្នាចង់ប្រាប់ពួកម៉ាកឯងដែរគឺនៅទីនេះគ្នាធ្វើការបាន១០០ដើមផ្កាឈូក គ្នាអាចសុំវិស្សមកាលបាន១០ដើមទៅលេងភពមួយទៀតដូចជាភពឋានកណ្តាលឬក៏ឋាននរក។

នៅក្នុងផ្កាឈូកមួយដើមមានរយៈពេលដប់ឆ្នាំនោះបើធៀបទៅនិងឋានមនុស្សលោក។ គ្នានៅមិនទាន់សុំច្បាប់ឈប់សំរាកនៅឡើយទេ ព្រោះតែគ្នាទើបមកដល់ចូលធ្វើការថ្មីៗ ចាំមើលបន្តិចទៀតបានគ្នាហ៊ានសុំ។ គ្នាពិតជាចង់ទៅលេងឋានមនុស្សម្តងទៀតដែរ អត់អីទេពួកម៉ាកនៅពេលដែលគ្នាបានច្បាប់ហើយគ្នានិងទៅកើតនៅក្នុងក្រុមគ្រួសារមួយហើយគ្នានឹងបានជួបពួកម៉ាកឯងម្តងទៀតមិនខាន។មានអី! គ្នានៅស្រែកស្រាបៀរទៀតដែរតើ។ ចាំពេលគ្នាបានច្បាប់ចាំគ្នាប្រាប់ពួកម៉ាកឯងថាគ្នានឹងទៅកើតជាមួយអ្នកណា គ្នាចង់ទៅលេងឋានមនុស្សរយៈពេលពី៦ទៅ៧ដើមផ្កាឈូកដែរ។

អ្ហឺមួយវិញទៀត ពួកម៉ាកឯងជួយទៅប្រាប់ទៅម៉ាក់ប៉ានិងក្រុមគ្រួសារគ្នាផង ថាកុំឲពួកគាត់ខ្វល់ខ្វាយអ្វីទៀត មិនយូរប៉ុន្មានទៀតទេពួកគាត់ទាំងអស់គ្នានិងបានមករស់នៅក្នុងវិមានជាមួយគ្នាមិនខាន។ ហើយពិសេសនោះដានិតរបស់គ្នានឹងនៅតែក្លាយទៅជាភរិយាទីមួយរបស់គ្នា នៅពេលដែលនាងអស់កម្មពារនៅឯឋានមនុស្សលោកនោះ។ ប្រាប់នាងផងថាគ្នាគិតពីនាងគ្រប់ពេល តែសូមនាងគួរបំភ្លេចគ្នាមួយរយៈសិនទៅ បំភ្លេចគ្នាក៏ដូចជាបំភ្លេចពេលវេលាដែលនាងត្រូវចាំមកជួបគ្នានោះដែរ។ នាពេលអនាគតដ៏ខ្លីពួកយើង ក៏នឹងមិនបានបែកគ្នាទៀតដែរ ព្រោះតែពួកយើងបានសងម្ចាស់កម្មរួចរាល់អស់ហើយ។

អ្វីដែលគ្នាចង់ឲពួកម៉ាកឯងធ្វើទៀតនោះគឺព្យាយាមយ៉ាងណាប្រាប់ដំណឹងទាំងនេះ ឲទៅដល់មនុស្សលោកទាំងឡាយឲស្គាល់និងយល់ឲច្បាស់ពីមេត្តានិងករុណារួមទាំងការចេះអត់អោនឲគ្នា

ផង។ ហើយប្រាប់ពួកគេផងដែរថាប្រសិនបើពួកគេបានប្រព្រឹត្តិអំពើល្អទាំងនេះ មិនយូរទេពួកគេនឹងបានរួចរាល់ទោសកម្មទាំងប៉ុន្មាននៅឯឋាននរក។

កុំភ័យពេលដែលគ្នាបានច្បាប់ឈប់សំរាកហើយ គ្នានឹងប្រាប់ទៅពួកម៉ាកឯងមុនគេថាគ្នានឹងទៅកើតនៅទីណាហើយពេលនោះហើយដែលយើងអាចសប្បាយជួបជុំគ្នាម្តងទៀតមែនទេ?

អ្វយេ! នៅទីបញ្ចប់គ្នាគ្រាន់តែប្រសិទ្ធិពរឱពួកម៉ាកនៅតែរក្សារចិត្តល្អរហូត ហើយពិសេសនោះសូមឱពួកម៉ាកឯងរស់នៅឱបានសប្បាយ នៅក្នុងរយៈពេលដែលពួកម៉ាកឯងត្រូវនៅលុបលាងបាបកម្មទាំងឡាយនៅក្នុងឋានមនុស្សលោក។

## ពួកយើងឃ្លាតតែកាយមែនពិត តែចិត្តយើងមិននៅឆ្ងាយពីគ្នាទេ!

ដោយសេចក្តីនឹករលឹកស្រលាញ់និងអាលោះអាល័យជាទីបំផុត!

ពីសំលាញ់អភ័ព្វរបស់ចាន់ណារិន

តៀន ការ

*****